ទំព័រទី១៖ ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣០

# ពណ៌នៃប្រទេសជប៉ុនដែលរស់រវើកជាមួយនិងអារម្មណ៍របស់អ្នក

ទំព័រទី២៖ មាតិកា

ទស្សនាវដ្ដីលេខនេះ និយាយអំពី "**ពណ៌នៃប្រទេសជប៉ុនដែលរស់រវើកជាមួយនិងអារម្មណ៍របស់អ្នក**"

- ពណ៌ទៅតាមពេលវេលា
- ពណ៌ក្នុងទីក្រុង
- ពណ៌ក្នុងភូមិឋាន៖ ទេសភាពនៃការនឹករឭក គឺជារបស់មានតម្លៃសម្រាប់អនាគត
- កេរ្តិ៍ដំណែលនានាទាក់ទងនឹងពណ៌នៃប្រទេសជប៉ុន
- សិល្បៈហត្ថកម្មភ្លឺចិញ្ចាចដោយពណ៌មាស៖ សិប្បករដំសន្លឹកមាស
- ទស្សនាសម្រស់ថ្ងៃលិចដ៏អស្ចារ្យ
- រសជាតិជប៉ុន៖ ពេលវេលាទទួលទាន! ត្ស៊ឹកិម៉ុណុ(ជ្រក់)
- ដើរកំសាន្តប្រទេសជប៉ុន៖ ខាម៉ាគឺរ៉ា
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ ឆត្របត់

គម្របសៀវភៅ៖ រូបទិដ្ឋភាពនាវដូវស្លឹកឈើជ្រុះមានពណ៌យ៉ាងស្រស់ស្អាតដូចអណ្ដាតភ្លើងឆេះ កំពុងលាបពណ៌លើផ្ទៃទឹក និងបេះដូងអ្នកទស្សនា។ *បឹងត្សឹតានឹម៉ា ក្នុងខេត្តអាអុម៉ូរិ*

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំមួយភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្ដី និប៉ុនិកា មានប្រភពមកពីពាក្យ "និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*ប្រភពរូបថត៖ គេហទំព័រអាម៉ាណាអ៊ិម៉េច* (amanaimages)

*លេខរូបថត* 30 R–030312

*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*

*២-២-១ កាស៊ុមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*

*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/

*(រូបថត) រូបស្លឹកម៉ុមិជិចម្រុះពណ៌ជ្រុះលើអាងទឹកលាងដៃ (ចាន ឬ អាងសម្រាប់លាងសម្អាតដៃ) ដែលគ្រប់ដណ្ដប់ដោយស្លែបៃតងនៅសួនច្បារជប៉ុន*

<u>ទំព័រទី៣</u>៖

ទស្សនាវដ្ដីលេខនេះ និយាយអំពី "**ពណ៌នៃប្រទេសជប៉ុនដែលរស់រវើកជាមួយនិងអារម្មណ៍របស់អ្នក**"

ពណ៌ទាំង៤រដូវបានផ្សារភ្ជាប់ដោយធម្មជាតិយ៉ាងសម្បូរបែប។ ការប្រើប្រាស់ពណ៌បែបប្រពៃណី បានរីកដុះដាលជាច្រើនជំនាន់។ ជប៉ុន មានពណ៌ជាច្រើនដែលទាក់ទងនឹងអារម្មណ៍ក្នុងចិត្ត។ យើងនឹងណែនាំអ្នកទៅកាន់ពិភពចម្រុះពណ៌ និងស៊ីជម្រៅនៃពណ៌ជប៉ុន ដែលបានមកពីការផ្លាស់ប្ដូរពណ៌បន្តិចបន្តួច។

<u>ទំព័រទី៤</u>៖

## ពណ៌នៅតាមពេលវេលា

***សូមរីករាយនឹងទេសភាពផ្លាស់ប្ដូរសន្សឹមៗទៅតាមដំណាក់កាលនៃពេលវេលា***

*រូបផ្នែកខាងលើ៖ ទេសភាពទៀបភ្លឺនៅភ្នំហ្វូជិ ហ៊ុមព័ទ្ធដោយពពកដេរដាសបានមកដល់នាពេលព្រឹកព្រលឹម*

*រូបផ្នែកខាងក្រោម៖ ពេលព្រឹកដ៏ស្ងប់ស្ងាត់ ពន្លឺថ្ងៃរះ ចាំងឆ្លុះនឹងសួនច្បារគ្របដណ្ដប់ដោយព្រិលសក្បុស។ សួនគេនរ៉ុគឹអេន នៅខេត្តអ៊ិស៊ិខាវ៉ា*

<u>ទំព័រទី៥</u>៖

*រូបស្ដាំផ្នែកខាងលើ៖ ទេសភាពដ៏ស្រស់បំព្រងនាពេលថ្ងៃជាមួយនឹងស្លឹកម៉ុមិជិ រស្មីចាំងផ្លេកៗអមជាមួយនឹងទឹកជ្រោះធ្លាក់ប្រសាច*

*រូបផ្នែកខាងក្រោម៖ ងូតទឹកក្រោមកម្ដៅថ្ងៃ អមដោយទេសភាពព្រៃឈើបៃតងខ្ចី ជាម្លប់ផ្ទៃទឹកដ៏ស្ងប់ស្ងាត់ បង្កើតនូវពណ៌ដ៏អស្ចារ្យរវាងពន្លឺ និងស្រមោល។ កោះគឹជូគឹ នៅខេត្តណាហ្គាសាគិ*

*ប្រភពរូបថត៖ គេហទំព័រអាម៉ាណាអ៊ិម៉េច* (amanaimages)

<u>ទំព័រទី៦</u>៖

*រូប៖ នៅក្រោមពន្លឺព្រះចន្ទពេញវង់រះយ៉ាងត្រចះត្រចង់ ជញ្ជាំងប្រាសាទពណ៌សដែលមានប្រវត្តិជាង៤០០ឆ្នាំនោះ បំភ្លឺក្នុងស្បែរាត្រី។ ប្រាសាទហ៊ិមេជិ នៅខេត្តហ្យូហ្គុ*

<u>ទំព័រទី៧</u>៖

*រូបផ្នែកខាងលើ៖ បរិវេណដ៏ល្បីងល្បើយ មានស្រះទឹកចំនួន៦ និងភ្នំសិប្បនិម្មិតចំនួន១៣។ ពន្លឺនៃទេសភាពចម្រុះពណ៌ និងភាពល្អឥតខ្ចោះ នៅលើផ្ទៃទឹកនាពេលថ្ងៃរៀបអស្តង្គត។ សួនរិត្សឺរិន នៅខេត្តខាហ្គាវ៉ា*
*រូបផ្នែកខាងក្រោម៖ ជម្រាលហាឈិម៉ានហ្សាកា លាតសសន្ធឹងទៅដល់កំពង់ផែហាកុដាតិ។ នៅពេលដល់ពេលវេលាដែលភ្លើងអំពូលបំភ្លឺតាមផ្លូវនោះ ដើមឈើដែលដុះជាជួរបង្ហាញនូវភ្លើងពណ៌ភ្លឺបភ្លែតៗយ៉ាងស្រស់ត្រកាល។ ហាកុដាតិ នៅខេត្តហុកកៃដូ*

*ប្រភពរូបថត៖ គេហទំព័រអាម៉ាណាអ៊ិម៉េច* (amanaimages)

<u>ទំព័រទី៨</u>៖

## ពណ៌ក្នុងទីក្រុង

*រូបផ្នែកខាងលើ៖ ដើមសាគូរ៉ា អ៊ីវ៉ាតារ៉ុ ដែលមានអាយុជាង១០០ឆ្នាំ*

**ពណ៌ផ្កាឈូក ឬ ពណ៌ផ្កាសាគូរ៉ារីក ទីក្រុងហ្គិរ៉ុ (ខេត្តហ្គិហ្វ៊ុ)**

ទីក្រុងហ្គិរ៉ុ មានទីតាំងនៅតំបន់ជូប៊ឺ (ផ្នែកកណ្ដាលនៃប្រទេសជប៉ុន) មានសណ្ឋានខុសគ្នាប្រមាណ២៨០០ម៉ែត្ររវាងភាគខាងជើង និងភាគខាងត្បូងនៃទីក្រុង ដូច្នេះ ទីក្រុងនេះ មានទេសភាពស្រស់បំព្រង ពោរពេញទៅដោយពណ៌ផ្កាសាគូរ៉ារីក ដែលអាចទស្សនាបានដោយក្ដីរីករាយនៅទីតាំងផ្សេងៗគ្នាសម្រាប់រយៈពេលប្រហែល មួយខែគិតចាប់ពីចុងខែមីនា។ មានដើមឈើចាស់ៗជាច្រើន ដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងសហគមន៍ ជាឧទាហរណ៍ ដើមសាគូរ៉ា អ៊ីវ៉ាតារ៉ុ ដែលត្រូវបាននិយាយតៗគ្នាថា ឈ្មោះបែបនេះ មានប្រភពមកពីបុព្វបុរសដែលបានដាំដើមឈើនេះ និងដើមសាគូរ៉ា ណាវ៉ាស៊ិរ៉ុ ត្រូវបានគេដាក់ឈ្មោះតាមទំនៀមទម្លាប់រឿងព្រេងនិទានចាស់របស់មនុស្សដែលរង់ចាំដើមឈើនេះមានផ្ការីកជាសញ្ញានៃការចាប់ផ្ដើមរៀបចំសំណាប (ណាវ៉ាស៊ិរ៉ុ)។

*រូបផ្នែកកណ្ដាល៖ បុណ្យតាណុកាមិ (អាទិទេពវាលស្រែ) ត្រូវបានគេស្គាល់ថាជាសញ្ញានៃរដូវផ្ការីក ឬ និទាឃរដូវ។ អ្នករបាំវ័យក្មេងស្លៀកសំលៀកបំពាក់ប្រពៃណីចម្រុះពណ៌ ហាណាហ្គាសា ដែលមានមួកថ្មែជាមួយផ្កាជាច្រើន។*

*រូបផ្នែកខាងក្រោម៖ ផ្លូវកុជិម៉ាខោខូវប៊យ*(Kojima Jeans Street) *លាតសន្ធឹងប្រហែង៤០០ម៉ែត្រ ស្របជាមួយនឹងហាងនានា ដែលដំណើរការដោយក្រុមហ៊ុនផលិតក្នុងស្រុកក្នុងចំណោមក្រុមហ៊ុននានា។*

*ប្រភពរូបថត៖ ទីក្រុងហ្គិរ៉ុ នៅខេត្តហ្គិហ្វ៊ុ*

<u>ទំព័រទី៩៖</u>

*រូបផ្នែកខាងលើ៖ ទីប្រជុំជនអូអ៊ុយឈិជីគី នៅរដូវរងា ជាមួយនឹងព្រិលសក្បុស*

**ពណ៌ស ឬ ពណ៌ព្រិល ទីប្រជុំជនអូឈិជីគី (ខេត្តហ្វ៊ឹគីស៊ីម៉ា)**

ចំពេលមានខ្យល់ត្រជាក់ ដំបូលប្រក់ស្បូវរាងទេរគ្របដណ្តប់ដោយព្រិលនោះ បានផ្តល់នូវអារម្មណ៍កក់ក្តៅ។ ទីប្រជុំជនអូអ៊ុយឈិជីគី បានបន្សល់នូវកេរ្តិ៍ដំណែលរបស់ខ្លួនថាជា "ទីប្រជុំជនប្រៃសណីយ៍" ជាកន្លែងដែលអ្នកធ្វើដំណើរនឹងឈប់សម្រាកក្នុងដំណើរផ្លូវឆ្ងាយរបស់ពួកគេ ហើយគេហដ្ឋានសម្រាប់សម្រាកជាជួរនេះ ពុំមានការប្រែប្រួលជាងបួនទសវត្សរ៍មកហើយ។ ដើម្បីការពារកេរ្តិ៍ដំណែលនៃតំបន់នេះសម្រាប់ក្មេងៗជំនាន់ក្រោយ ទីប្រជុំជននេះមានច្បាប់លំនៅដ្ឋានមួយដែលមានគោលការណ៍មូលដ្ឋានចំនួន៣គឺ ហាមមិនឱ្យលក់ ជួល ឬ កំទេចចោល។ សហគមន៍ក៏បានព្យាយាមសិក្សាបន្ថែម និងចែករំលែកនូវវិធីសាស្ត្រប្រក់ដំបូលស្បូវដើម្បីថែរក្សានូវទេសភាពដែលមិនអាចកាត់ថ្លៃនោះ។

**នៅខែធ្នូ ឆ្នាំ២០២០ «ជំនាញ វិធីសាស្ត្រ និងចំណេះដឹងបែបប្រពៃណីក្នុងការថែរក្សា និងការបន្តស្ថាបត្យកម្មឈើនៅប្រទេសជប៉ុន» ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ លើផ្នែកសម្បត្តិវប្បធម៌អរូបិយ ក្នុងនោះមានដំបូលស្បូវផងដែរ។*

*រូបផ្នែកកណ្តាល៖ សិប្បករប្រក់ដំបូលស្បូវដែលត្រូវបានគេហៅថា ខាយ៉ាតិ ជាអ្នកដឹកនាំ ហើយប្រជាជនរស់នៅទីនោះសហការគ្នាប្រក់ដំបូលស្បូវឡើងវិញ។*

*ប្រភពរូបថត៖ សមាគមទេសចរណ៍អូអ៊ុយឈិជីគី*

**ពណ៌ទឹកប៊ិច ឬ ពណ៌ធ្លះ ស្រុកកុជិម៉ា (ខេត្តអូកាយ៉ាម៉ា)**

ផ្លូវកូជិម៉ាខោខូវប៊យ(Kojima Jeans Street) ជំរុញនូវវត្តមានដ៏ល្អប្លែក ក្នុងទីក្រុងគឺរ៉ាស៊ិគិ ដែលស្ថិតនៅម្ខាងនៃសមុទ្រសិតុ នៅប្រទេសជប៉ុនភាគខាងលិច។ វាត្រូវបានគេស្គាល់ថា ជាទីតាំងទីមួយនៅប្រទេសជប៉ុន ដែលផលិតខោខូវប៊យ និងបន្តជាមជ្ឈមណ្ឌលសិប្បករពិតប្រាកដ។ ពណ៌ធ្លះ(藍の色(ai no iro) អៃ ណុ អ៊ិរ៉ុ : indigo) គឺត្រូវបានបង្កើតជាស្រទាប់យ៉ាងល្អិតល្អន់ និងសង្កត់ពណ៌បន្ថែមដោយការជ្រលក់ក្រណាត់ ការច្របាច់បញ្ចូលគ្នា និងដាក់សំដិលឱ្យត្រូវខ្យល់ដើម្បីឱ្យមានប្រព្រឹត្តកម្ម និងត្រូវធ្វើបែបនេះម្តងហើយម្តងទៀត។ ការជ្រលក់ពណ៌ដោយសិប្បករជំនាញ ពណ៌ធ្លះត្រូវបានទទួលស្គាល់ថាជាពណ៌ជិត និងពណ៌ជាប់យូរមិនងាយនឹងហើរពណ៌។

*រូបផ្នែកខាងក្រោម៖ សិប្បករជំនាញជ្រលក់ពណ៌ធ្លះម្នាក់ កំពុងជ្រលក់ពណ៌អំបោះ ដើម្បីប្រើប្រាស់សម្រាប់សិប្បកម្មនានា។*

*ប្រភពរូបថត៖ សភាពាណិជ្ជកម្ម និងឧស្សាហកម្មកុជិម៉ា ក្រុមហ៊ុនជប៉ុនប្លូ(Japan Blue)*

*ប្រភពរូបថត៖ PIXTA*

<u>ទំព័រទី១០</u>៖

*រូបផ្នែកខាងលើ៖ ព្រៃយ៉ាគឹស៊ិម៉ាបៃតងស្រស់ គឺត្រូវបានគេស្គាល់ថាជាទីជម្រកនៃដើមតាត្រៅ ជារុក្ខជាតិដែលដុះលូតលាស់នៅប្រទេសជប៉ុន។*

**ពណ៌បៃតង យ៉ាគឹស៊ិម៉ា កោះយ៉ាគឹស៊ិម៉ា (ខេត្តខាហ្គុស៊ិម៉ា)**

នៅកោះយ៉ាគឹស៊ិម៉ា អ្នកអាចរកឃើញនូវព្រៃក្រាស់ និងអាចិកំបាំងគ្របដណ្តប់ដោយស្លែដុះពេញ។ នៅពេលដែលអ្នកដើរដល់ចម្ងាយសម្គាល់៥០០ម៉ែត្រ ដើមតាត្រៅ (ដែលបានស្គាល់ពីអ្នកកោះនោះថា មានអាយុយ៉ាងហោចណាស់ក៏១០០០ឆ្នាំដែរ) នឹងចាប់ផ្តើមបង្ហាញសម្រស់ខ្លួន។ ដើមតាត្រៅដែលរឹងមាំ និងល្បីល្បាញថាជាដើមតាត្រៅចូម៉ុន មានអាយុកាលចំណាស់ជាងគេ ប្រហែលចាប់ពីចន្លោះ២០០០ឆ្នាំ ទៅ៧២០០ឆ្នាំឯណោះ។ សត្វដែលមានដើមកំណើតនៅទីនោះជាច្រើនរស់នៅលើទឹកដីពណ៌បៃតងមួយនេះជាយូរមកហើយ ដូចជា សត្វស្វាយ៉ាគឹស៊ិម៉ា។

*រូបផ្នែកកណ្តាល៖ សត្វស្វាយ៉ាគឹស៊ិម៉ា សម្រាកនៅតាមផ្លូវ។*

*រូបផ្នែកខាងក្រោម៖ វិហារអ៊ិណារិ ហ្វ៊ឹស៊ិមិ ជានិមិត្តរូបនៃ ហ្វ៊ឹស៊ិមិ។*

<u>ទំព័រទី១១</u>៖

*រូបផ្នែកខាងលើ៖ សោភ័ណភាពសណ្ឋានគែមនៃសំណង់អាគារឈើ*

**ពណ៌ត្នោត ឬ ពណ៌ឈើ ទីប្រជុំជនណារ៉ាអ៊ិជឹគឹ (ខេត្តណាហ្គាណុ)**

ស្ថិតនៅអមជាមួយនឹងលំនៅដ្ឋានប្រមាណជា៣០០ខ្នង ណារ៉ាអ៊ិជឹគឹ គឺជាទីប្រជុំជនប្រៃសណីយ៍មួយដែលវែងជាងគេក្នុងចំណោមទីប្រជុំជនផ្សេងទៀតនៅប្រទេសជប៉ុន។ ក្នុងសម័យអេដុ (១៦០៣-១៨៦៨) ទីប្រជុំជននេះ ពោរពេញទៅដោយភ្ញៀវទេសចរទៅនិងមក នៅលើផ្លូវណាកាសិនដុ ស្ថិតតាមបណ្តោយទន្លេណារ៉ាអ៊ិ នៅខេត្តណាហ្គាណុ ប្រទេសជប៉ុនភាគកណ្តាល។ សណ្ឋានទីប្រជុំជន គឺលាតសន្ធឹងប្រមាណ១គីឡូម៉ែត្រ ជាមួយនឹងសំណង់អាគារធ្វើពីឈើនៃស្ថាបត្យកម្មដ៏ល្អប្លែក រួមបញ្ចូលទាំងមុខងារ និងសិល្បៈ ដែលបង្កើតនូវអារម្មណ៍ស៊ីជម្រៅ និងគ្មានទីកំណត់។

*ប្រភពរូបថត៖ ទីក្រុងស៊ិអុជិរិ នៅខេត្តណាហ្គាណុ*

**ពណ៌ក្រហមព្រឿង ទីប្រជុំជនហ្វូស៊ិមិ (ខេត្តក្យូតូ)**

ទីប្រជុំជននេះ មានវិហារអ៊ិណារិ ហ្វូស៊ិមិ ដែលជាទីគួរឱ្យចងចាំដោយមានច្រកទ្វារតុរិអ៊ិពណ៌ក្រហមព្រឿងៗ ហាក់ដូចជាបង្ហាញសម្រស់ច្បាស់ ហើយក៏ជាស្រុកស្រាសាកេល្បីល្បាញរបស់ប្រទេសជប៉ុនផងដែរ។ ការផលិតស្រាសាកេ គឺត្រូវការបរិមាណទឹកដ៏ច្រើនសម្បើម ហើយហ្វូស៊ិមិ គឺភូមិឋានប្រភពទឹកធម្មជាតិប្រកបដោយគុណភាពខ្ពស់ និងមានរឿងជាច្រើនទាក់ទងនឹងប្រភពទឹក។ នៅពេលដែល កានហ្ស៊ីគិរិ (ការបិទស្រានៅរដូវត្រជាក់) ឈានដល់កម្រិតកំពូលក្នុងពេលរៀបចំនៅរដូវរងា ចំហាយក្លិនឈ្ងុយឈ្ងុបរបស់ស្រាពីអង្ករចំហុយ សាយភាយពេញទីប្រជុំជន។

*រូបផ្នែកខាងក្រោម៖ ដំណើរការមុនប្រែក្លាយជាស្រាសាកេ ត្រូវបានគេហៅថា ម៉ូរ៉ុមិ (ការផ្អាប់ស្រាសាកេ)។ នេះគឺជាដំណើរការដែលចំណាយរយៈពេលប្រហែលពី២០ ទៅ៣០ថ្ងៃ។*

*ប្រភពរូបថត៖ ក្រុមហ៊ុនហ្គេកកេកានសាកេ* (Gekkeikan Sake)

*ប្រភពរូបថត៖* PIXTA

<u>ទំព័រទី១២</u>៖

**ពណ៌ក្នុងភូមិឋាន៖** ទេសភាពនៃការនឹករឭក គឺជារបស់មានតម្លៃសម្រាប់អនាគត

*ផ្នែកខាងលើរូប៖ ទិដ្ឋភាពទូទៅ នៃភូមិសាតុយ៉ាម៉ា។ ភ្នំជាច្រើននៅផ្នែខាងក្រោយផ្ទះ ឈរតំរៀបគ្នាជាជួរការពារប៉មផ្ទះ។ ទីនេះ គឺហ៊ុមព័ទ្ធទៅដោយព្រៃចម្រុះ ទន្ទឹមនឹងវាលស្រែពណ៌បៃតងលាតសន្ធឹងដូចលំហានៅផ្នែខាងមុខ។*

*ជាងថត៖ អ៊ិម៉ាម៉ូរិ មិត្ស៊ឹហ៊ិកុ* (Imamori Mitsuhiko)

សម្រាប់ជនជាតិជប៉ុន ពាក្យថា សាតុយ៉ាម៉ា (មានន័យថា «ភូមិ និងភ្នំ») បង្ហាញពីភាពកក់ក្តៅ និងការនឹករឭកដល់ស្រុកកំណើតរបស់ខ្លួន។ សាតុយ៉ាម៉ា គឺជាតំបន់ដែលធម្មជាតិត្រូវបានកកើតឡើង តាមវិធីសាស្រ្តទូទៅរបស់មនុស្សផ្សារភ្ជាប់នឹងធម្មជាតិ ហើយមានឧទាហរណ៍ជាច្រើនដូចជាវាលស្រែ ប្រឡាយ ទីវាល និងព្រៃឈើចម្រុះ។ នៅទីនេះ ការរួមរស់របស់មនុស្សជាមួយនឹងធម្មជាតិ បង្កើតបានជាជីវិតប្រកបដោយគតិបណ្ឌិត និងជំនាញជាច្រើនដែលបន្តពីមួយជំនាន់ទៅមួយជំនាន់។

ឧទាហរណ៍ជាក់ស្តែង មនុស្សប្រើប្រាស់សាតុយ៉ាម៉ា ជាទីកន្លែងប្រមូលថាមពល និងធនធានដូចជា ឈើអុស និងសម្ភារៈសំណង់អាគារ ព្រមទាំងម្ហូបអាហារ ដូចជារុក្ខជាតិព្រៃជាដើម។ ដោយរក្សាការពារបាននូវទីជម្រករបស់រុក្ខជាតិ និងសត្វ ពួកគេនឹងបង្កើតនូវប្រព័ន្ធអេកូឡូស៊ីមួយដ៏ល្អប្លែកផងដែរ។ នេះគឺជាការផ្សារភ្ជាប់ទៅនឹងជីវៈចម្រុះ

នៅសាតុយ៉ាម៉ា ព្រមទាំងអត្ថប្រយោជន៍ដ៏សម្បូរបែបរបស់វា ដែលជាទ្រព្យសម្បត្តិមិនអាចកាត់ថ្លៃបានរបស់ប្រជាជនជប៉ុន។

ទោះបីជាយ៉ាងនេះក៏ដោយ ប៉ុន្មានឆ្នាំកន្លងមកនេះ ការថយចុះនៃចំនួនប្រជាជននៅសហគមន៍ជនបទ និងកត្តាផ្សេងៗទៀត បាននាំឱ្យកើតមានការមិនយកចិត្តទុកដាក់ និងភាពសឹករេចរិលនៃសាតុយ៉ាម៉ា បណ្ដាលឱ្យមានស្ថានភាពរអិលបាក់ដី និងផលប៉ះពាល់អវិជ្ជមានដល់សត្វព្រៃតាមរយៈការថយចុះនៃជីវៈចម្រុះ។ ដើម្បីថែរក្សាការពារសាតុយ៉ាម៉ា ដែលលម្អដោយបរិស្ថានធម្មជាតិជាច្រើននោះ វាត្រូវតែទទួលបាននូវការថែរក្សាការពារសម្រាប់ឱ្យបានដល់កូនចៅជំនាន់ក្រោយ ហើយយើងត្រូវតែស្វែងរកវិធីសាស្ត្រថ្មីឱ្យមានការចូលរួមដែលចុះសម្រុងទៅនឹងរបៀបរស់នៅរបស់ប្រជាជន ដូចជាតាមរយៈគំនិតផ្តួចផ្តើមនានាដែលផ្សារភ្ជាប់ទៅនឹងឧស្សាហកម្មក្នុងស្រុក។

ដោយការព្រួយបារម្ភនឹងលក្ខខណ្ឌនានានៃសាតុយ៉ាម៉ា ជាងថតរូបលោក អ៊ិម៉ាម៉ូរិ មិត្សឹហ៊ិកុ (Imamori Mitsuhiko) បានចាប់ផ្តើមរស់នៅក្បែរបឹងប៊ិវ៉ា ដែលជាបឹងធំជាងគេនៅប្រទេសជប៉ុន នៅខេត្តស៊ិហ្គា។ ការងារដែលគាត់ផ្តោតការយកចិត្តទុកដាក់លើ គឺការផ្តិតយកសកម្មភាពប្រជាជនដែលរស់នៅទីនោះ ក៏ដូចជាផ្តិតយករូបភាពភាវៈមានជីវិតនានាដូចជាផ្កា ដើមឈើ សត្វល្អិតក្នុងបរិស្ថានធម្មជាតិរបស់ពួកគេ។ លោកបានបង្កើនប្រជាប្រិយភាព និងណែនាំពីសារៈសំខាន់នៃជីវិតនៅសាតុយ៉ាម៉ា ដោយពិពណ៌នានូវសម្រស់ធម្មជាតិនៃភូមិនេះ-ទិដ្ឋភាពទូទៅ និងការនឹកនាទៅកាន់ប្រជាជនជប៉ុន តាមរយៈទម្រង់កំណាព្យដ៏ពេញនិយម។ លោក អ៊ិម៉ាម៉ូរិ មានប្រសាសន៍ថា «ខ្ញុំមិនមានបំណងថតទិដ្ឋភាព សាតុយ៉ាម៉ាដែលបាត់រូបរាងនោះទេ» លោកបន្តថា «ទាំងនេះគឺជាទេសភាពសម្រាប់អនាគត»។ ជាជាងការពិចារណាថាវាជាកម្មវត្ថុពឹងផ្អែកលើអារម្មណ៍ គាត់ប្រហែលកំពុងស្រមៃទម្រង់ពិតរបស់សាតុយ៉ាម៉ា ដែលជាបណ្តុំនៃជីវិតគ្រប់ទម្រង់។

<u>ទំព័រទី១៣</u>៖

*រូបទី១៖ វាលស្រែជាជួរត្រូវបានដាំដុះនៅនិទាឃរដូវ។ ទាំងនេះគឺដូចជាពំនូក បង្កើតបានពំនូកដីនៅចន្លោះវាលស្រែ។ ចបកាប់ត្រូវបានប្រើដើម្បីកាប់គាស់ និងធ្វើពំនូកដីការពារកុំឱ្យទឹកហូរចេញក្រៅ។*

*រូបទី២៖ ផ្លែទន្លាប់ស៊ិប៊ឹហ្គាគិ (ផ្លែទន្លាប់មានរសជាតិចត់) ត្រូវបានចងភ្ជួរក្រោមស្នូរ ឱ្យក្លាយជា ហុស៊ិហ្គាគិ (ទន្លាប់ក្រៀម)។ នៅពេលទន្លាប់ក្រៀម រសជាតិចត់ត្រូវបានបន្សាប ហើយជំនួសមកនូវទន្លាប់ដែលផ្អែម និងរសជាតិឆ្ងាញ់ពិសារ។*

*រូបស្តាំផ្នែកខាងលើ៖ ដើមទន្លាប់ចាស់ ដែលជាសញ្ញារដូវប្រមូលផលនៅសាតុយ៉ាម៉ា។*

*រូបទី៣៖ អំឡុងរដូវរងានៅសាតុយ៉ាម៉ា សិល្បៈក្រងចំបើងធ្វើដោយដៃ ត្រូវបានបង្កើតឡើង។ សព្វថ្ងៃនេះ សិល្បៈនេះធ្វើក្នុងទម្រង់ជាចំណាប់ចំណូលចិត្តដើម្បីកុំឱ្យភ្លេចនូវវិធីសាស្ត្រនានា។*

*រូបទី៥៖ កៅអីត្បាញពីចំបើងវេញជាក្រឡាស្មើៗគ្នាដែលធ្វើហើយរួចរាល់។*

*រូបស្តាំផ្នែកកណ្តាល៖ វាលស្រែជាថ្នាក់ៗ នៅសិសិរដូវ គ្របដណ្តប់ដោយពណ៌មាស រាងដូចត្រចៀកវាលស្រែ សំដិលខ្លួនក្រោមកម្តៅថ្ងៃ និងត្រៀមខ្លួនរួចរាល់ក្នុងការប្រមូលផល។*

ជាងថតរូប លោកអ៊ីម៉ាម៉ូរិ មិត្ស៊ឹហ៊ិកុ (Imamori Mitsuhiko)

លោក គឺជាជាងថតរូបនាំមុខគេនៅសាគុយ៉ាម៉ា។ យោងតាមការរៀបរាប់របស់លោក ជាមួយនឹងទិដ្ឋភាពនៃបឹងប៊ិវ៉ា នៅខេត្តស៊ិហ្គា លោកផ្តិតយករូបភាពនានាក្រោមប្រធានបទ ទាំងធម្មជាតិជុំវិញ ទាំងទំនាក់ទំនងរវាងមនុស្ស និងធម្មជាតិ។ ជាញឹកញាប់ លោកក៏ធ្វើដំណើរ និងផ្តិតយករូបភាពតាមតំបន់ដាច់ស្រយាល ចាប់ពីតំបន់ព្រៃត្រូពិក រហូតដល់វាលខ្សាច់ពាសពេញពិភពលោក និងទទួលស្គាល់ជាអន្តរជាតិផងដែរ។ លោកត្រូវបានគេទទួលស្គាល់តាមរយៈការទទួលបានពានរង្វាន់ជាច្រើន រួមមានពានរង្វាន់លើគុណសម្បត្តិវប្បធម៌ក្នុងតំបន់ពីរដ្ឋមន្ត្រីក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃប្រទេសជប៉ុន។

<u>ទំព័រទី១៥៖</u>

## **កេរ្តិ៍ដំណែលនានាទាក់ទងនឹងពណ៌នៃប្រទេសជប៉ុន**

ឈ្មោះពណ៌ប្រពៃណីរបស់ប្រទេសជប៉ុនច្រើនតែមានការយោងទៅលើវត្ថុសិប្បកម្ម ឬ ចំណុចទាក់ទងយ៉ាងស៊ីជម្រៅនៃផលិតផលនោះ។ ការប្រសព្វដាក់ឈ្មោះទាំងនេះ បង្ហាញពីការយល់ដឹងដ៏ឈ្លាសវៃ និងប្រុងប្រយ័ត្នដែលប្រជាជនជប៉ុនមានចំពោះពណ៌ដែលនៅជុំវិញខ្លួន។

នៅក្នុងសង្គមសម័យទំនើប នៅពេលដែលយើងកាន់តែទទួលរងនូវឥទ្ធិពលនៃវត្ថុគ្មានជីវិត និងមានសណ្ឋានដូចគ្នាបេះបិទ ដូចជាទូរទស្សន៍ កុំព្យូទ័រ និងទូរសព្ទដៃ ធ្វើឲ្យសិប្បកម្មប្រពៃណីដែលត្រូវបានចម្រាញ់ឡើងក្នុងប្រវត្តិសាស្ត្រ មានក្រណាត់ក្បាច់ក្បូរដ៏ល្អិតល្អន់ និងពណ៌ដ៏ស៊ីជម្រៅនៅក្នុងជីវិតរបស់យើង បានលេចធ្លោ ហើយមានវត្តមានខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

សូមក្រឡេកមើលឱ្យកាន់តែជិតដល់ នូវការយល់ដឹងរបស់ជនជាតិជប៉ុនដែលប្រកបដោយការគិតគូរ និងវិភាគចំពោះពណ៌តាមរយៈសិប្បកម្ម ជាកំណប់ទ្រព្យដែលបានរក្សាទុកគ្រប់ជំនាន់។

**ពណ៌ខ្មៅ និងពណ៌ក្រហម៖ ពណ៌បុរាណនៃម្រ័ក្សណ៍ខ្មុកជប៉ុន**

នៅពេលគូររូបដាក់ពណ៌ប្រណិតប្លែកនៃម្រ័ក្សណ៍ខ្មុកជប៉ុន គឺពណ៌ខ្មៅ និងក្រហម មើលទៅទំនងជាត្រូវចិត្តរបស់យើង (រូបទី១)។

ពណ៌ក្រហម គឺជាម្រ័ក្សណ៍ខ្មុកដំបូងគេដែលបានមកដល់ប្រទេសជប៉ុន វាគឺប្រហែល ៩,០០០ឆ្នាំមុន អំឡុងដើមសម័យចូម៉ុន (Jomon) (គិតចាប់ពីពេលបច្ចុប្បន្ននេះទៅប្រហែល ៧,០០០ ទៅ ១២,០០០ឆ្នាំមុន)។

ពណ៌ក្រហមត្រូវបានចាត់ទុកថាជាពណ៌ពិសិដ្ឋតំណាងឲ្យភ្លើង ឈាម និងព្រះអាទិត្យ។ នៅសម័យចូម៉ុនសម្រាប់ហេតុផលអបិយជំនឿ ម្រ័ក្សណ៍ក្រហមអ៊ុរឹស៊ិ (sekishoku urushi - ម្រ័ក្សណ៍ជប៉ុន ដែលជាថ្នាំពណ៌ជ័រធម្មជាតិកែច្នៃពីរុក្ខជាតិ) ត្រូវបានគេលាបច្រើនដងនៅលើស្និតសិតសក់ និងភាជន៍ ។ ក្រោយមក នៅសម័យយ៉ាយ៉ុយ (Yayoi) (សតវត្សរ៍ទី១-៣) ម្រ័ក្សណ៍ខ្មៅអ៊ុរឹស៊ិ(kokusyoku urushi) បានដើរតួរយ៉ាងសំខាន់ ដែលអាចសន្និដ្ឋានបានថា ដោយសារតែអបិយជំនឿនៃសម័យចូម៉ុន បានរសាត់បាត់ទៅ ហើយនៅពេលនោះគេផ្តោតសំខាន់មើលទៅលើរូបរាង និងមុខងាររបស់ភាជន៍វិញ។

ម្រ័ក្សណ៍ក្រហមអ៊ុរឹស៊ិ មានពីរក្រុម ដែលពួកវាខុសគ្នាដោយសារប្រភពដើមនៃសារធាតុពណ៌។ មួយគឺសារធាតុពណ៌បារតក្រហម(Cinnabar) ដែលប្រើសារធាតុពណ៌ក្រហមជាមួយបារតស៊ុលហ្វីត(mercury sulfide) ដែលជាសមាសធាតុសំខាន់របស់វា ហើយមួយទៀតគឺ សារធាតុពណ៌ជាតិដែកអុកស៊ីត (Bengala) ដែលជាសារធាតុពណ៌ក្រហមត្នោត កើតពីការដុតដីក្រហមដែលមានផ្ទុកសារធាតុដែកអុកស៊ីត (Ferric oxide)។ សារធាតុពណ៌ជាតិដែកអុកស៊ីត (Bengala) ត្រូវបានប្រើមិនត្រឹមតែសម្រាប់ម្រ័ក្សណ៍ខ្មុករបស់ជប៉ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ការលាបពណ៌លើវត្ថុសេរ៉ាមិក និងអគារផងដែរ។

ម្រ័ក្សណ៍ខ្មៅអ៊ុរឹស៊ិ ត្រូវបានបង្កើតឡើងដោយការលាយម្សៅដែក(iron powder) និងផេះខ្មៅ(soot) ដែលជាម្សៅកាបូនម៉ត់កើតចេញពីការឆេះមិនសព្វនៃជ័រស្រល់ ប្រេង និងខ្លាញ់ និងជាវត្ថុផ្សេងៗទៀត។

*ស្នាដៃគ្រួសារ ត៊្សុយស៊្សឺ យ៉ូហ្សេ ជំនាន់ទី២០* (Tsuishu Yozei XX) "*កំប៉េះ ឬ គោកចម្លាក់រូបផ្កាប្រាំមួយ*" *ឆ្នាំ១៩១៥ នៅសារមន្ទីរសិប្បកម្មជាតិ*

*នៅក្នុងស្នាដៃនេះ ពណ៌ខ្មៅ និងពណ៌ក្រហមតែមួយគត់របស់ម្រ័ក្សណ៍ខ្មុកអ៊ុរឹស៊ិ* (urushi) *ត្រូវបានធ្វើឡើងយ៉ាងប្រណិត។ ទន្ទឹមនឹងការរក្សាបច្ចេកទេសនៃការឆ្លាក់ គំរូម្រ័ក្សណ៍ខ្មុកអ៊ុរឹស៊ិត្រូវបានគេលាបជាស្រទាប់ ហើយលោក ត៊្សុយស៊្សឺ បានបន្ថែមគំនិតនៃរូបរាងបែបទំនើបសម្រាប់ការងាររបស់លោក។*

ទំព័រទី១៥៖

កុលាលភាជន៍មីម្យ៉ូអ៊ិ (Mumyoi) ដែលផលិតនៅកោះសាដុ (Sado) ខេត្តនីហ្គាតា (Niigata) គឺជាគ្រឿងស្មូនធ្វើពីដីឥដ្ឋក្រហមក្នុងស្រុកដែលមានផ្ទុកជាតិដែក។ លោក អ៊ិតុ សិគិស៊ុអិ ជំនាន់ទី៥ (Ito Sekisui V) គឺជាជាងស្មូនដ៏ជំនាញនាពេលបច្ចុប្បន្ន ដែលបានប្រើប្រាស់ដីឥដ្ឋពណ៌ក្រហមស្រស់ និងដីឥដ្ឋពណ៌លឿងដែលប្រមូលបាននៅសាដុ(Sado) ដើម្បីបង្កើតពណ៌ចម្រុះដ៏ល្អនៅលើស្នាដៃដំរលោងស្អាតដូចធ្វើនៅលើសាច់ក្រណាត់(រូបទី២)។ ភាពរស់រវើកដ៏មានឥទ្ធិពលដែលមនុស្សយើងទំនងជាទទួលអារម្មណ៍ថាពណ៌ក្រហមនៅសម័យបុរាណហាក់បីដូចជាកំពុងរំជើបរំជួលយ៉ាងជ្រៅនៅក្នុងក្បាច់(pattern)ដ៏អស្ចារ្យនេះ។

**ពណ៌ខៀវ៖ ពណ៌ដូចដែលបានឃើញក្នុងគ្រឿងស្មូន ការជ្រលក់ពណ៌ និងតម្បាញ**

ពណ៌នៃថ្នាំរលោង(釉薬(uwagusuri): glaze) នៃគ្រឿងស្មូន មានការផ្លាស់ប្តូរយ៉ាងខ្លាំង មុន និងក្រោយពេលដុតរួច។ ថ្នាំរលោងត្រូវបានបង្កើតឡើងដោយការរំលាយដីឥដ្ឋជាមួយនិងទឹក ហើយបន្ទាប់មកលាយជាមួយនិងផេះឈើ ផេះចំបើង ឬ សមាសធាតុលោហៈសម្រាប់បង្កើតពណ៌។ ដូច្នេះហើយ មុនពេលដុត វាគឺជាអង្គធាតុរាវពណ៌ប្រផេះ ប៉ុន្តែនៅពេលដែលលាបនឹងភាជន៍ ហើយដុតវានៅក្នុងឡ នោះវាបានប្រែពណ៌ដែលមិននឹកស្មានដល់ ដូចជាពណ៌ខៀវថ្លា ពណ៌គុជថ្លើមថ្ម ឬ ពណ៌ផ្កាឈូកខ្ចីជាដើម។ ជាងស្មូនបានដុតម្តងហើយម្តងទៀតនូវបំណែកសាកល្បងជាច្រើននៅក្នុងឡ ដោយព្យាយាមគ្រប់គ្រងការផ្លាស់ប្តូរបន្តិចបន្តួចនៃពណ៌រហូតដល់កម្រិតអតិបរមា។

សេរ៉ាមិចមួយប្រភេទដែលទាក់ទាញជាងស្មូនជាច្រើនគឺ សេជិ (青磁(seiji)សំដៅលើកុលាលភាជន៍មានពណ៌ខៀវបៃតង ឬ ភាសាអង់គ្លេសហៅថា Celadon)។ ជាតិដែក (鉄分(tetsubun): ferric oxide) ដែលនៅក្នុងថ្នាំរលោង មានប្រតិកម្មគីមីទៅនឹងភ្លើង ធ្វើឲ្យមានការប្រែពណ៌ចាប់ពីពណ៌ខៀវភ្លឺ រហូតដល់ពណ៌ខៀវបៃតង។ នៅក្នុងនោះក៏មាន សេជិ ដែលមានពណ៌ថ្លាស្រដៀងទៅនឹងមេឃស្រឡះបន្ទាប់ពីភ្លៀងហើយ ដែលចាត់ទុកថាជា ម៉ាបុរ៉ុស៊ិ ណុ សេជិ (幻の青磁(maboroshi no seiji) : illusive treasure សំដៅលើកំណប់ទ្រព្យបញ្ឆោតភ្នែក) បានក្លាយជាគោលដៅចង់បានយ៉ាងខ្លាំងសម្រាប់អ្នកប្រមូលទិញ។ ដោយសារតែ សេជិ ដែលដុតបានយ៉ាងល្អ ត្រូវបានផ្តល់ជូនសម្រាប់តែអ្នកដែលមានឋានៈខ្ពស់ ដែលមនុស្សទូទៅពិបាកចូលទៅក្បែរវា ហើយក៏មិនត្រូវបានអនុញ្ញាតឱ្យឃើញដោយងាយស្រួលផងដែរនោះ ពណ៌នៃសេជិនេះ ក៏ត្រូវបានគេហៅថា ពណ៌ហ៊ិសុគឺ (hisoku-ពណ៌លាក់ពួន)។

*ស្នាដៃរបស់ លោក អ៊ិតុ សិគិស៊ុអិ ជំនាន់ទី៥ (Ito Sekisui V) "ចានមីម្យ៉ូអ៊ិ (Mumyoi) រូបផ្កា ផលិតផលខេត្តនីហ្គាតា" ឆ្នាំ២០១៥, ការប្រមែប្រមូលរបស់បុគ្គលឯកជន។*

*ដីឥដ្ឋក្រហមនៅសាដូ (Sado) ដែលប្រមូលបាននៅជុំវិញតំបន់ អៃកាវ៉ា មាស និង ប្រាក់ (Aikawa Gold & Silver Mine)។ វាមានផ្ទុកជាតិដែកច្រើន។*

*ស៊ិមិហ្ស៊ុ អ៊ុអ៊ិឈិ (Shimizu Uichi) "ចានគោមសេជិ" ឆ្នាំ១៩៧៣ នៅសារមន្ទីរសិប្បកម្មជាតិ*

*វាមានរូបប្រេះរាប់មិនអស់ ដែលត្រូវបានគេហៅថាគុំរូជ្រៀតចូលថ្នាំរលោង ហើយបានបង្កើនប្រសិទ្ធភាពដែលមិនអាចពិពណ៌នាបាន។*

<u>ទំព័រទី១៦៖</u>

ដោយការគោរពចំពោះអត្ថន័យនៃពាក្យ ពណ៌ហ៊ិសុគឹ (hisoku-ពណ៌លាក់ពួន) លោក ស៊ិមឹរ៉ា ហ្វូគឹមិ (Shimura Fukumi) ជាអ្នកតម្បាញ និងជ្រលក់ពណ៌ បានមើលឃើញពណ៌នេះនៅក្នុងបរិបទនៃវាយនភណ្ឌ ដែលទាក់ទងនឹងពណ៌ទឹកប៊ិច ឬ ពណ៌ផ្ទះ(indigo) ដែលលេចចេញជារូបរាងនៅក្នុងដំណើរការជ្រលក់ពណ៌។ ដំណាក់កាលចុងក្រោយនៃ អៃដាតិ (aidate) (ការងារជ្រលក់ថ្នាំដើម្បីឲ្យវាចេញពណ៌ផ្ទះ លើសរសៃអំបោះជាដើម) ដែលមានពណ៌ផ្ទះស្រាល និងបាត់ពណ៌ខៀវ ខណៈពេលដែលគេបានបន្តដេញពណ៌លើសរសៃអំបោះផ្សេងទៀតលើពណ៌ដែលកាត់រវាងពណ៌កាប់ស្តាំងស្រាល(ultramarine)  និងពណ៌ខៀវស្រាល (pastel blue) (ពណ៌កណ្តាលរវាងពណ៌ខៀវចាស់បៃតងស្វាយ និងពណ៌ខៀវខ្ចីបៃតងស)។ អៃដាតិ គឺស្រដៀងទៅនឹងជីវិតរបស់មនុស្សដែលបានកើតធំលូតលាស់ឡើង និងវ័យចំណាស់ ហើយមានតែនៅពេលដែលវាមកដល់ដំណាក់កាលចុងក្រោយដោយសុវត្ថិភាពទេ ទើបយើងអាចឃើញ "ពណ៌ដ៏ស៊ីជ្រៅ និងអាថ៌កំបាំង" (ស៊ិមឹរ៉ា ហ្វូគឹមិ (Shimura Fukumi), 1982, ពណ៌មួយជីវិតមួយ, គ្យ៊ូរ្យ៊ូដូ (Kyuryudo) ) ដែលជាពណ៌លោកស្រី ស៊ិមឹរ៉ា ស្រឡាញ់។

**ពណ៌ត្នោត ឬពណ៌តែ និងពណ៌ស្វាយ៖ ពណ៌ពេញនិយមនៅអេដូ**

នៅក្នុងសម័យអេដូ (១៦០៣-១៨៦៨) ពណ៌ត្នោត ឬ ពណ៌តែ និងពណ៌កណ្តុរប្រផេះ មានការពេញនិយមយ៉ាងធំទូលាយដែលត្រូវបានគេបង្កើតជាពណ៌ខុសគ្នាបន្តិចបន្តួចរហូតដល់គេលើកឃ្លាមួយឡើងថា "ស៊ិជីហាត់ចា ហ្យាគឹណិហ្ស៊ុមិ (shijyuuhatcha-hyakunezumi)" (មានន័យត្រង់ថា ពណ៌តែ៤៨ ពណ៌កណ្តុរប្រផេះ១០០)។ យោងទៅតាមឋានៈសង្គមនៃសម្លៀកបំពាក់ដែលត្រូវបានហាមប្រាមយ៉ាងតឹងរឹងនាពេលនោះ ដើម្បីញែកខ្លួនពួកគេចេញពីការរឹតបន្តឹងទាំងនោះ ក្នុងចំណោមអ្នកដែលចូលចិត្តការលេងម៉ូដ បានក្លាយជាកាតាលីករមួយដែលមានឆន្ទៈយ៉ាងមោះមុត ដើម្បីបង្កើតពណ៌ដ៏ស្រស់ស្អាត និងស្រទន់។ បច្ចេកទេស និងអារម្មណ៍ខាងផ្លូវចិត្ត ក្នុងការបែងចែកពណ៌យ៉ាងល្អិតល្អន់សម្រាប់ការជ្រលក់ពណ៌ត្រូវបានធ្វើឡើងក្នុងប្រវត្តិសាស្ត្រជប៉ុនតាំងពីសម័យបុរាណ។

ជាឧទាហរណ៍ ពណ៌ស្វាយបានកាន់តំណែងខ្ពស់បំផុតក្នុងយុគសម័យអធិរាជសុយកុ(Suiko) (គ្រងរាជ្យ ៥៩២-៦២៨ នៃគ.ស) ហើយមិនអាចស្លៀកពាក់ពណ៌នេះដោយគ្មានការអនុញ្ញាតពីព្រះចៅអធិរាជឡើយ។

*រូបលេខ៥៖ ទឹកត្រាំពណ៌សម្រាប់ការជ្រលក់ពណ៌ទឹកប៊ិច ឬ ពណ៌ខ្លះ(indigo)។ រូបថត៖ អាម៉ាណាអ៊ីម៉េច (amanaimages)*

*រូបលេខ៦៖ លោកស្រី ស៊ិមឹរ៉ា ហ្វូគឹមិ (Shimura Fukumi) «សម្លៀកបំពាក់គិម៉ុណុ, "មិហ្សឺរីរី", សូត្រត្ស៊ឹមឹហ្គិ (Kimono, "Lapis Lazuli Blue", tsumugi silk )» ឆ្នាំ១៩៧៦, សារមន្ទីរសិប្បកម្មជាតិ*
*សម្រេចបានពណ៌ខៀវស្រាល និងងងឹតនៅដំណាក់កាលអៃដាតិ(aidate)។*

*រូបលេខ៧៖ មិយ៉ាហ្គាវ៉ា កុហ្សាន ជំនាន់ទី១ (Miyagawa Kozan I) «ថូផ្កា, រចនាម៉ូតផ្កាអាយ៉ាមិ ឬ ផ្កាអាយរីស(Iris), បាញ់ថ្នាំរលោងអេណាម៉េល(underglaze enamels)» កំឡុងឆ្នាំ១៨៩៧–១៩១២ សារមន្ទីរសិប្បកម្មជាតិ*
*ផ្កាអាយរីសពណ៌ខៀវ គឺជាពណ៌ប្រពៃណីមួយរបស់ប្រទេសជប៉ុន។*

<u>ទំព័រទី១៧៖</u>

នៅក្នុង សៀវភៅអេនហ្គិស៊ិគិ (Engishiki) ជាសៀវភៅច្បាប់ និងទំនៀមទម្លាប់របស់ប្រទេសជប៉ុន សម័យហេអាន (Heian) (៧៩៤-១១៨៥) ដែលត្រូវបានសរសេរចប់នៅឆ្នាំ៩២៧នៃគ.ស និយាយអំពីពណ៌ត្រូវបានបែងចែកដោយមិនត្រឹមតែពណ៌ស្វាយចាស់ និងពណ៌ស្វាយខ្ចីប៉ុណ្ណោះទេ ប៉ុន្តែក៏មាន ពណ៌ស្វាយចាស់បែកប្រផេះផងដែរ។ លើសពីនេះទៀតសម្ភារៈសម្រាប់ការជ្រលក់ពណ៌ត្រូវបានគ្រប់គ្រងយ៉ាងលម្អិត។ នៅសម័យអេដុ ភាពជាប់ពាក់ព័ន្ធរបស់ពណ៌ស្វាយនៃឋានៈតុលាការព្រះចៅអធិរាជបានខ្សោយទៅៗ ហើយត្រូវបានគេលាបពណ៌ជាច្រើន ដូចជាពណ៌ស្វាយស្រស់ (ដោយប្រើឫសស្មៅពណ៌ស្វាយ (紫草(murasakikusa) ធ្វើជាថ្នាំជ្រលក់ពណ៌) ពណ៌ស្វាយបែកក្រហម ឬ ហៅថា ក្យូមឹរ៉ាសាគិ(京紫(kyomurasaki)) ពណ៌ស្វាយបែកខៀវ ឬ ហៅថា អេដុមឹរ៉ាសាគិ(江戸紫(edomurasaki)) និងពណ៌ស្វាយផ្សេងទៀត ដែលក្រុមគ្រួសារសាម៉ូរ៉ៃ និងអ្នកទីក្រុងចូលចិត្ត។

ការយល់ឃើញរបស់ជនជាតិជប៉ុនក្នុងការបែងចែកពណ៌យ៉ាងល្អិតល្អន់ គឺប្រើប្រាស់មិនត្រឹមតែចំពោះសម្លៀកបំពាក់ប៉ុណ្ណោះទេ ប៉ុន្តែប្រើដើម្បីលម្អិតការតុបតែងដ៏តូចបំផុតផងដែរ។ បច្ចេកវិទ្យាបានអភិវឌ្ឍយ៉ាងខ្លាំងចំពោះការដាក់ពណ៌លើគ្រឿងដែក ដើម្បីតុបតែងដាវដែលសៀតនៅចង្កេះ ខណៈពេលដែលបានបង្ហាញនូវលក្ខណៈសម្បត្តិខាងក្នុងរបស់វាឡើងមក។ ជាឧទាហរណ៍ លោហធាតុប្រាក់-ទង់ដែង អាចបង្ហាញពីពណ៌កណ្តុរប្រផេះងងឹត ទៅជាពណ៌កណ្តុរប្រផេះភ្លឺ ដោយបង្កើន ឬ បន្ថយសមាធាតុប្រាក់។ វាត្រូវបានគេយកមកអនុវត្ត ដើម្បីបង្ហាញឱ្យឃើញថារោមសត្វស្លាបដោយលោហៈ គឺដូចនឹងផ្ទាំងគំនូរទេសភាពដែលប្រើទឹកថ្នាំគូរលើក្រដាសដូចគ្នា។ បច្ចេកវិទ្យានេះបានរីកដុះដាលក្នុងវិស័យសិប្បកម្មនាំចេញតាំងពីសម័យមេជិ (Meiji) (១៨៦៨-១៩១២)។

**ពណ៌សះ ការបង្ហាញអារម្មណ៍នៃពណ៌ដែលទន់ភ្លន់**

ទោះបីជាយ៉ាងណាក៏ដោយ ម្រ័ក្សណ៍អ៊ុរីស៊ិ(urushi)ពណ៌សសុទ្ធ មិនអាចផលិតបានទេ ដោយសារតែធម្មជាតិនៃធាតុផ្សំរបស់វា។ ផ្ទុយទៅវិញ នៅពេលដែលចង់បានពណ៌ស គេប្រើធាតុផ្សំដែលរួមបញ្ចូលជាមួយសំបកលៀស ឬ គ្រំ និងសំបកស៊ុត ដើម្បីទាញអត្ថប្រយោជន៍ពីលក្ខណៈដ៏ល្អឥតខ្ចោះនៃម្រ័ក្សន៍អ៊ុរីស៊ិ ជាសារធាតុស្អិតវិញ។ នៅពេលប្រើសំបកលៀស ឬ គ្រំ ស្រទាប់ខាងក្នុងនៃគុជខ្យង ដែលចាំងផ្លាតពណ៌ឥន្ទធនូរបស់វាត្រូវបានប្រើប្រាស់ជាបន្ទះស្តើងៗ។ ប៉ុន្តែនៅពេលគេលាបថ្នាំរ៉ែ ឬ ថ្នាំលាបផ្សេងទៀតនៅផ្នែកខាងខ្នង នោះពណ៌នឹងបង្ហាញយ៉ាងស្រទន់តាមរយៈលៀស ឬ គ្រំ ដូចជាការមើលតាមស្បៃ។ បច្ចេកទេសនេះត្រូវបានគេហៅថាហ្វូសិហ្សៃស៊ិគិ (fusezaishiki) ដែលមានន័យត្រង់ថា "ពណ៌លាក់បាំង" ហើយត្រូវបានគេប្រើដើម្បីតុបតែងកញ្ចក់ និង កាំបិតដែលបានរក្សាទុកនៅឃ្លាំងស្យ៉ូសូអ៊ីន (Shosoin)។

ជាមួយនឹងវិធីសាស្ត្រស្រដៀងទៅនឹងហ្វូសិហ្សៃស៊ិគិ វាក៏ត្រូវបានប្រើសម្រាប់គំនូរ និងសេរ៉ាមិចរបស់ជប៉ុនផងដែរ (រូបថតទី៩) ដែលវាជាភស្តុតាងថា ប្រជាជនជប៉ុនចាប់អារម្មណ៍លើលទ្ធផលដ៏ល្អឆើតទាំងនេះ។ តាមរយៈរស្មីពណ៌សនៃលៀស ឬ គ្រំ វាបានបង្ហាញអាថិកំបាំងដែលមានយ៉ាងជ្រាលជ្រៅក្នុងនោះ។ នេះជាឧទាហរណ៍ច្បាស់លាស់នៃអារម្មណ៍ផ្លូវចិត្តរបស់ប្រជាជនជប៉ុន ដែលចាត់ទុកភាពទន់ភ្លន់ជាគុណធម៌។

*រូបលេខ៨៖ ស៊ីហ្ស៊ុគិ ចូគិឈិ (Suzuki Chokichi)«ស្នាំងសំរិទ្ធជប់ពីរ (ស្នាំង៨)» ឆ្នាំ១៨៩៣, សម្បត្តិវប្បធម៌ដ៏សំខាន់, សារមន្ទីរសិប្បកម្មជាតិ៖ ពណ៌ត្រូវបានបែងចែកដោយនៅផ្នែកខ្នងមានរោមប្រាក់ និងរោមពណ៌ទង់ដែងនៅផ្នែកខាងក្រោមពីកដល់ពោះ*

*រូបលេខ៩៖ អ៊ិតាយ៉ា ហាហ្សាន (Itaya Hazan) «ថូផ្កា, រចនាចម្លាក់លិប, បាញ់ពណ៌រលោង(underglaze color) ហើយលាបថ្នាំរលោងភ្លាស(mat glaze)» ឆ្នាំ១៩២២, សារមន្ទីរសិប្បកម្មជាតិ៖ ផ្ទៃពណ៌ពីក្រោមថ្នាំរលោងស្រិល។*

*រូបភាព (ទំព័រទី១៤ ក្រដាសវ៉ាស៊ិ (Washi)៖ ក្រដាសប្រពៃណីជប៉ុនធ្វើដោយដៃ)៖ PIXTA*

*លោកស្រី គិតាមឹរ៉ា ហ៊ិតុមិ (Kitamura Hitomi) ជាអ្នកជំនាញរៀបចំការតាំងពិពណ៌សិល្បៈ (Curator), ប្រធានផ្នែកសិប្បកម្ម នៃនាយកដ្ឋានសិប្បកម្ម នៃសារមន្ទីរសិប្បកម្មជាតិ។ លោកស្រី មានជំនាញក្នុងប្រវត្តិសាស្ត្រសិប្បកម្មទំនើប។ ការតាំងពិពណ៌នាពេលថ្មីៗនេះរួមមាន "គ្រឿងសង្ហារឹមរបស់លោក ម៉ាសែល ព្រួយ៉ា(Marcel Breuer)៖ Improvement for good" (សារមន្ទីរជាតិនៃសិល្បៈសម័យទំនើប ទីក្រុងតូក្យូ ឆ្នាំ២០១៧) និង "ស្នាដៃសិល្បៈទំនើបៗពីការប្រម៉ែប្រមូលរបស់សារមន្ទីរ–ការតាំងបង្ហាញពិសេស៖ Modern Tea Caddies" (វិចិត្រសាលសិប្បកម្ម, សារមន្ទីរជាតិនៃសិល្បៈសម័យទំនើប ទីក្រុងតូក្យូ ឆ្នាំ២០១៨)។*

ទំព័រទី១៨៖

## សិល្បៈហត្ថកម្មភ្លឺចិញ្ចាចដោយពណ៌មាស

## សិប្បករដំសន្លឹកមាស

សន្លឹកមាស ត្រូវបានបង្កើតឡើងដោយការបញ្ចូលគ្នានៃលោហៈធាតុមាសសុទ្ធជាមួយប្រាក់ និងទង់ដែងបន្តិចបន្តួច រហូតដល់កម្រាស់យ៉ាងស្តើងប្រហែល ១/១0,000មីលីម៉ែត្រ។ វាត្រូវបានគេប្រើដើម្បីតុបតែងឲ្យកាន់តែអស្ចារ្យ លើស្ថាបត្យកម្ម រូបចម្លាក់ សិល្បៈ និងសិប្បកម្ម ក៏ដូចជារបស់របរប្រើប្រាស់ប្រចាំថ្ងៃជាច្រើនផ្សេងទៀត។ បច្ចេកទេសនៃការធ្វើសន្លឹកមាសដ៏មានតម្លៃឱ្យក្លាយជាបន្ទះយ៉ាងស្តើង គឺជាគន្លឹះដែលត្រូវបានផលិតភាគច្រើននៅក្នុងខាណាហ្សាវ៉ា ខេត្តអ៊ិស៊ិកាវ៉ាសព្វថ្ងៃ។

លោក ម៉ាត់ស៊ឹមឹរ៉ា គេនអ៊ិឈិ (Matsumura Kenichi) គឺជាសិប្បករម្នាក់ដែលបានបង្កើតសន្លឹកមាសអស់រយៈពេលជាង ៥០ឆ្នាំនៅខាណាហ្សាវ៉ា។ លោកពន្យល់ឲ្យដឹងថា "សិល្បៈហត្ថកម្ម គឺជាពាក្យមានន័យដូចការអត់ធ្មត់" ព្រោះការផលិតសន្លឹកមាស គឺទាមទារភាពអំណត់អត់ធ្មត់ដែលពាក់ព័ន្ធនឹងដំណើរការដដែលៗរាប់មិនអស់។

វិធីសាស្ត្រនៃការផលិតសន្លឹកមាសហៅថា អេនត្ស៊ឹកិ (Entsuke) ដែលមានប្រពៃណីជាង៤០០ឆ្នាំ នៅខាណាហ្សាវ៉ា ត្រូវបានកំណត់លក្ខណៈពិសេសដោយការប្រើក្រដាសស្តើងៗសម្រាប់ដំ(foil-beating pater) ដើម្បីពន្លាតសន្លឹកមាស។ វាត្រូវបានគេនិយាយថា គុណភាពនៃក្រដាសស្តើងៗសម្រាប់ដំនេះ គឺកំណត់ថ្នាក់ចុងក្រោយនៃសន្លឹកមាស ដូច្នេះសិប្បករចំណាយពេលវេលាយ៉ាងសំខាន់ក្នុងការរៀបចំក្រដាសនេះ។ វ៉ាស៊ិ (Washi) (ក្រដាសធ្វើដោយដៃបែបប្រពៃណីរបស់ជប៉ុន) ត្រូវយកមកលាយជាមួយល្បាយដីពិសេស ដោយត្រូវត្រាំក្នុងទឹកក្បុងចំបើង ឬ ឧបករណ៍ផ្ទុកផ្សេងទៀត ពេលវាស្ងួតគ្រប់គ្រាន់ហើយ ត្រូវដាក់ត្រាំដដែលបែបហ្នឹងម្តងហើយម្តងទៀតជាច្រើនដង។ នៅពេលដែលក្រដាសស្តើងៗសម្រាប់ដំបានបញ្ចប់ ផ្ទៃរបស់វានឹងមានភាពរលោងស្អាត ហើយវាសាកសមសម្រាប់ការពន្លាតសន្លឹកមាស។

វាជាជំហានបន្ទាប់ដែលសិប្បករសន្លឹកមាស បត់បែនតាមជំនាញរបស់ខ្លួន ដោយធ្វើឱ្យសន្លឹកមាសទៅជាបន្ទះស្តើងៗគួរឲ្យភ្ញាក់ផ្អើល។ សិប្បករត្រូវកាត់ និងបែងចែកសន្លឹកមាសដែលកាត់រួចដោយម៉ាស៊ីន ហើយបញ្ចូលដុំមាសនីមួយៗទៅក្នុងចន្លោះក្រដាសស្តើងៗសម្រាប់ដំនោះពី១,៨០០សន្លឹក រួចហើយ ដាក់វាដំដោយញញួរម៉ាស៊ីនប្រហែលកន្លះថ្ងៃ។ បន្ទាប់មក សិប្បករនឹងផ្ទេរសន្លឹកមាសនីមួយៗដែលដំហើយនោះ ទៅក្នុងក្រដាសស្តើងៗសម្រាប់ដំនោះឲ្យច្រើនជាងមុន ហើយដំវាបន្ថែមទៀតដោយម៉ាស៊ីន។ សិប្បករពឹងផ្អែកលើការពិចារណា

របស់គាត់ក្នុងអំឡុងពេលជាច្រើនម៉ោងដែលវាត្រូវការដើម្បីដំសន្លឹកមាសទាំងនោះឲ្យទៅជាស្តើងៗបំផុត។ ជាចុងក្រោយ សន្លឹកមាសត្រូវកាត់ក្នុងទំហំ១០៩ម.ម ជារាងការ៉េ ហើយកិច្ចការនេះនឹងបានបញ្ចប់រួចរាល់ជាស្ថាពរ។

*រូបលើផ្នែកខាងឆ្វេង៖ សន្លឹកមាសដែលមិនអាចខ្វះបានសម្រាប់សិប្បកម្មប្រពៃណីដូចជាផ្ចិតជាដើម។*

*រូបក្រោមផ្នែកខាងស្តាំ៖ សន្លឹកមាសដែលត្រូវបានគេដំយ៉ាងស្តើងរហូតដល់អាចមើលឃើញម្ខាងទៀតបាននោះ គឺទាមទារបទពិសោធន៍ និងជំនាញជាច្រើនឆ្នាំរបស់សិប្បករ។*

*រូបក្រោមផ្នែកខាងឆ្វេង៖ ការផលិតក្រដាសស្តើងៗសម្រាប់ដំ គឺជាកត្តាយ៉ាងសំខាន់សម្រាប់គុណភាពនៃសន្លឹកមាស ហើយវាគឺជាកិច្ចការដ៏យូរ និងចំណាយពេលច្រើន។*

*១. បញ្ចូលសន្លឹកមាសដែលកាត់ម្តងមួយៗចូលទៅក្នុងក្រដាស១,៨០០សន្លឹក។*

<u>ទំព័រទី១៩៖</u>

*២. កញ្ចប់ក្រដាសបិទសន្លឹកមាសត្រូវបានរុំដោយស្បែក និងដំដោយម៉ាស៊ីន។*

*៣. បន្ទាប់ពីផ្ទេរសន្លឹកមាសដែលបានដំហើយទៅលើក្រដាសស្តើងៗសម្រាប់ដំ ហើយដំដោយម៉ាស៊ីនម្តងទៀត។*

*៤. បន្ទាប់ពីដំវាដល់កម្រិតហើយ សន្លឹកមាសត្រូវបានលាតឱ្យបានល្អ។*

*៥. កាត់សន្លឹកមាសម្តងមួយៗ ដោយកាំបិតរាងស៊ុមការ៉េ។*

*៦. សន្លឹកមាសដ៏ប្រណិតអាចខ្ទេចខ្ទីបានដោយគ្រាន់តែប៉ះម្រាមដៃ ដូច្នេះឧបករណ៍បុរាណដែលធ្វើពីឫស្សីនេះ ត្រូវបានប្រើប្រាស់សម្រាប់ការពារពីចរន្តអគ្គិសនីបិតិវន្ត(static electricity)។*

*រូបស្តាំផ្នែកកណ្តាល៖ សន្លឹកមាសដែលរួចរាល់ជាស្ថាពរ*

លោក ម៉ាត្ស៊ឹមឹរ៉ា (Matsumura) កើតនៅខាណាហ្សាវ៉ា ហើយត្រូវបានបណ្តុះបណ្តាលដោយឪពុករបស់លោកដែលជាសិប្បករសន្លឹកមាសចុងក្រោយ ហើយលោកក៏បន្តជំនាញផលិតសន្លឹកមាសនេះ។ លោកមានប្រសាសន៍ដោយក្រឡេកមើលទៅពេលដែលលោកបានហ្វឹកហាត់ថា "មិនមានសៀវភៅណែនាំជាលាយលក្ខណ៍អក្សរនៅក្នុងពិភពនៃសិប្បកម្មតំណពូជទេ"។ លោកបន្ថែមទៀតថា "កាលនោះ គាត់ប្រាប់ថាឱ្យបង្កើតជំនាញដោយខ្លួនឯងតាមរយៈការសង្កេត។ ខ្ញុំបានរៀនដោយការមើលលើស្នារបស់គាត់ ហើយធ្វើត្រាប់តាមគាត់ ដើម្បីស្រូបបច្ចេកទេសនោះចូលមកក្នុងខ្លួនរបស់ខ្ញុំ"។

លោក ម៉ាត់ស៊ឹមឹរ៉ា មានប្រសាសន៍ដោយទន់ភ្លន់នៅក្នុងកែវភ្នែករបស់លោកថា "សន្លឹកមាសតែងតែត្រូវបានផលិតនៅជុំវិញពិភពលោក ប៉ុន្តែសន្លឹកមាសរបស់ខាណាហ្សាវ៉ា គឺមានពន្លឺយ៉ាងស្រទន់ និងមានភាពកក់ក្តៅជាពិសេស"។

ឥឡូវនេះលោកកំពុងធ្វើការដើម្បីបន្តស្នាដៃដល់មនុស្សជំនាន់ក្រោយ។ ដោយមានការសាទរយ៉ាងខ្លាំងពីសិប្បករ រស្មីភ្លឺចិញ្ចាចនៃសន្លឹកមាសនឹងមិនសាបសូន្យឡើយ។

** នៅខែធ្នូ ឆ្នាំ២០២០ ត្រូវបានគេសម្រេចចិត្តចុះឈ្មោះ "ជំនាញបច្ចេកទេសស្ថាបត្យកម្មប្រពៃណីបុរាណៈ ជំនាញបច្ចេកទេសប្រពៃណីបុរាណនៃមរតកស្ថាបត្យកម្មឈើនៅក្នុងប្រទេសជប៉ុន" ដែលមាន ១៧ជំនាញបច្ចេកទេស រួមទាំងវិធីសាស្ត្រនៃការផលិតសន្លឹកមាសហៅថា អេនត្ស៊ឹកិ* (Entsuke) *នៅក្នុងបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបីមនុស្សជាតិរបស់អង្គការយូណេស្កូផងដែរ។*

*ថតដោយ តាគិស៊ិម៉ា យ៉ូជិ* (Takishima Yoji) *រូបភាពដោយ* PIXTA

***លោក ម៉ាត់ស៊ឹមឹរ៉ា កេនអ៊ិជិ*** (Matsumura Kenichi) ***សិប្បករផលិតសន្លឹកមាសប្រពៃណីខាណាហ្សាវ៉ា***

*លោកបានបង្កើតសមាគមអភិរក្សជំនាញបច្ចេកទេសបុរាណសន្លឹកមាសខាណាហ្សាវ៉ា*(Kanazawa Gold Leaf) *ក្នុងគោលបំណងដើម្បីទទួលមរតកជំនាញបច្ចេកទេសដែលបានទទួលពីឪពុករបស់លោក។ ក្នុងនាមជាប្រធានសមាគម លោក និងកូនប្រុសទីពីររបស់លោក ឈ្មោះ ណូរិយ៉ឺគិ* (Noriyuki) *ដែលជាសិប្បករផលិតសន្លឹកមាសផងដែរ ក៏កំពុងបង្កើតសកម្មភាពយ៉ាងស្វាហាប់ ដើម្បីបញ្ជូនសន្លឹកមាសទៅកាន់មនុស្សជំនាន់ក្រោយ។ លោកបានទទួលពានរង្វាន់ជាច្រើនដូចជា ពានរង្វាន់លើកកម្ពស់ជំនាញឧស្សាហកម្មប្រពៃណីខេត្តអ៊ិស៊ិខាវ៉ា ក្នុងឆ្នាំ១៩៨៩ និងពានរង្វាន់របស់ទីភ្នាក់ងារសម្រាប់កិច្ចការវប្បធម៌នៃប្រទេសជប៉ុនក្នុងឆ្នាំ២០១៩។*

<u>ទំព័រទី២០៖</u> **ដំណើរកំសាន្តជាក់ស្តែងទូទាំងប្រទេសជប៉ុន**

# ទស្សនាសម្រស់ថ្ងៃលិចដ៏អស្ចារ្យ

ក្នុងពេលដ៏ខ្លីមុនពេលថ្ងៃលិច ទិដ្ឋភាពដ៏អស្ចារ្យ និងដូចវេទមន្តត្រូវបានបង្ហាញ។ តោះទៅមើលថ្ងៃលិចដ៏ស្រស់ស្អាត ដែលអាចមើលឃើញតែនៅទីនេះ មិនមានដូចនៅកន្លែងណាផ្សេងទៀតទេ។

*រូបភាពដោយអាម៉ាណាអ៊ិម៉េច* (amanaimages)

**ឧបទ្វីបអុហ្គា (ទីក្រុងអុហ្គា)**

ទិដ្ឋភាពពេលល្ងាចដ៏អស្ចារ្យកំពុងរង់ចាំនៅស៊ិអុស៊ិហ្សាគិ នៅចុងភាគនិរតីនៃឧបទ្វីបនេះ។ នៅទីនេះមានថ្មដែលមានឈ្មោះហៅក្រៅថា "ថ្មហ្គូស៊ិឡា (Godzilla Rock)" ដោយសារតែរូបរាងរបស់វាមានលក្ខណៈស្រដៀងទៅនឹងហ្គូស៊ិឡា ជាបិសាចប្រឌិតដែលលេចឡើងក្នុងខ្សែភាពយន្តជប៉ុន។

ឆ្នេរឈិឈិប៊ីហ្គាហាម៉ា (ទីក្រុងមិតុយ៉ុ)

នៅពេលដែលជំនោរចុះទាប ហើយមិនមានខ្យល់បក់មកលើផ្ទៃទឹក នោះជំនោរផ្ទៃទឹក (ថ្លុកទឹក) នៅលើឆ្នេរខ្សាច់បានក្លាយទៅជាដូចកញ្ចក់។ អ្នកទស្សនាវីកែវាយនឹងការចាំងផ្លាតពីផ្ទៃមេឃនឹងថ្លុកទឹកនោះ ដែលធ្វើឱ្យវាក្លាយជាកន្លែងពេញនិយមនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ។

ស្ពានយ៉ុប៊ឹកុ អូហាស៊ិ (ទីក្រុងខារ៉ាត៊្សឹ)

ស្ពានយ៉ុប៊ឹកុ អូហាស៊ិ មានរូបរាងដ៏ស្រស់ស្អាតដែលមើលទៅស្រដៀងនឹងខ្សែពិណ។ នៅចំកណ្តាលស្ពានដែលមានប្រវែង៧២៨ម៉ែត្រ ព្រះអាទិត្យកំពុងបន្ទាបខ្លួនបន្តិចម្តងៗ បានចូលទៅដល់បេះដូងអ្នកធ្វើដំណើរ។

<u>ទំព័រទី២១៖</u>

ស្ពាននឹសាម៉ៃ (ទីក្រុងគឹស៊ិរ៉ុ)

ថ្ងៃលិចនៅគឹស៊ិរ៉ុ ត្រូវបានគេនិយាយថាជាថ្ងៃលិចមួយក្នុងចំណោមថ្ងៃលិចកំពូលទាំងបីនៅលើពិភពលោក។ ក្នុងនោះស្ពាននឹសាម៉ៃ មានភាពល្បីល្បាញសម្រាប់ជាចំណុចទស្សនីយភាពដ៏អស្ចារ្យនៃព្រះអាទិត្យលិច ដែលត្រូវបានគេនិយាយថាវាស្រស់ស្អាតជាពិសេស ក្នុងអំឡុងពេលរដូវស្លឹកឈើជ្រុះដល់រដូវរងានៅពេលដែលផ្ទៃមេឃស្រឡះ។

ឆ្នេរណាណាអ៊ឺរ៉ា (ទីក្រុងសាដុ)

ឆ្នេរណាណាអ៊ឺរ៉ា ត្រូវបានគេស្គាល់ថាជាកន្លែងមើលទេសភាពដ៏ស្រស់ស្អាតនៃទិដ្ឋភាពថ្ងៃលិចដ៏ពិសេសពីឆកណាហ្គាតិនៅចំកណ្តាលនោះ។ ឆ្នេរសមុទ្រលាតសន្ធឹងនេះផ្តល់នូវភាពសម្បូរបែបនៃទេសភាពជាមួយនឹងការចោត់ថ្នាក់នៃថ្មដែលមានរាងប្លែកៗ និងទិដ្ឋភាពដ៏អស្ចារ្យ គ្របដណ្តប់ដោយពន្លឺពណ៌ក្រហមឆ្អៅ។

ហាយ៉ាម៉ា (ស្រុកមិអ៊ឺរ៉ា)

នៅពេលដែលព្រះអាទិត្យលិចជិតកំពូលភ្នំហ្វូជិ ពន្លឺព្រះអាទិត្យបញ្ចេញរស្មីដូចពេជ្រ ដែលនាំឱ្យត្រូវបានគេហៅថា "ពេជ្រហ្វូជិ (Diamond Fuji)"។ ទិដ្ឋភាពពិសេសនេះអាចមើលឃើញបានត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះក្នុងមួយឆ្នាំនៅរដូវផ្ការីក និងរដូវស្លឹកឈើជ្រុះ។

ទំព័រទី២២៖ **រសជាតិនៃប្រទេសជប៉ុន៖ ពេលវេលាទទួលទាន**! ⑲

## គុបរិភោគអាហារដែលមានពណ៌ចម្រុះ

## **ត្ស៊ឹកិម៉ូណុ**(**ជ្រក់**)

ត្ស៊ឹកិម៉ូណុ (Tsukemono) ឬ ជ្រក់ សំដៅលើមុខម្ហូបដូចជា បន្លែ ផ្លែឈើ រុក្ខជាតិព្រៃ ផ្សិត ប្រភេទអាហារសមុទ្រ សារ៉ាយសមុទ្រ ឬ ប្រភេទសាច់ និងមានគ្រឿងផ្សំជាច្រើនប្រភេទទៀត ដែលប្រឡាក់ជាមួយអំបិល ទឹកស៊ីអ៊ីវ ទឹកខ្មេះ កន្ទក់(nuka) មិសុ(miso) និងដំបែ(kouji) ជាដើម។ ដោយរក្សាបាននូវរសជាតិដើមនៃគ្រឿងផ្សំ វាបានក្លាយជាជ្រក់ដែលមានរសជាតិប្រៃល្មម ដែលសមស្របនឹងរសជាតិបាយដ៏ឆ្ងាញ់។ វាគឺជាមុខម្ហូបជាទីពេញចិត្ត និងមិនអាចខ្វះបានសម្រាប់គុអាហាររបស់ជនជាតិជប៉ុនជាមួយបាយដែលបានដើរតួជាអាហារសំខាន់ជាយូរមកហើយ។

ជ្រក់មានប្រភេទផ្សេងៗគ្នា។ ឧទាហរណ៍ ជ្រក់ខ្លះត្រូវបានធ្វើឡើងដោយការផ្អាប់ ខ្លះទៀតដោយការដាក់គ្រឿងទេសរសជាតិជាដើម។ សូម្បីតែគ្រឿងផ្សំដូចគ្នាក៏ដោយ ក៏អាចធ្វើឱ្យយើងរីករាយជាមួយនឹងរសជាតិផ្សេងៗគ្នា ដោយសារការផ្លាស់ប្តូរពេលវេលានៃការធ្វើជ្រក់នោះ។ គ្រឿងផ្សំស្រស់ដែលយកមកជ្រក់បែបស្រាលៗ ហៅថា អាសាហ្ស៊ឹកិ (asazuke) ដែលធ្វើឡើងក្នុងពេលដ៏ខ្លី និងជ្រក់បែបចាស់ ហៅថា ហ្វូរឹហ្ស៊ឹកិ (furuzuke) គឺទុករយៈពេលយូរ ហើយវានឹងបង្កើតរសជាតិកាន់តែជិត ព្រមទាំងអាចរក្សាទុកក្នុងរយៈពេលយូរថែមទៀត។

នៅប្រទេសជប៉ុន តំបន់នីមួយៗបង្កើតជ្រក់ផ្ទាល់ខ្លួន ដោយប្រើប្រាស់ផលិតផលពិសេសក្នុងស្រុក ដើម្បីបង្កើនរសជាតិជ្រក់ទាំងនោះ។ នៅហុកកៃដូ មានជ្រក់ម្យ៉ាងឈ្មោះថា និស៊ីន-ហ្ស៊ឹកិ (nishin-zuke) ដែលធ្វើឡើងដោយចំណិតត្រីហារ៉ុងស្ងួតជាមួយស្ពៃក្តោបជាដើមដោយប្រើដំបែដើម្បីជ្រក់។ នៅក្នុងខេត្តអាគិតាមានជ្រក់ហៅថាអ៊ិប៊ឹរិហ្គាក់កុ(iburigakko) ដែលធ្វើឡើងដោយការឆ្អើរឆៃថាវ ហើយប្រើកន្ទក់ដើម្បីជ្រក់។ នៅខេត្តណាហ្គាណុផ្តល់ជូនជ្រក់ម្យ៉ាងហៅថាណុហ្សាវ៉ាណា-ហ្ស៊ឹកិ(nozawana-zuke) ដែលប្រើបន្លែស្លឹកស្រស់ៗជ្រក់។ ក្រៅពីនេះ មើមធូនីប (ស្រដៀងមើមឆៃថាវ) ត្រូវបានយកមកធ្វើជ្រក់ ដោយនៅតូក្យូ ហៅថា បេតិរ៉ា-ហ្ស៊ឹកិ (bettara-zuke) ដែលមានរសជាតិផ្អែម ចំណែកនៅទីក្រុងក្យូតុ ត្រូវបានគេហៅថា ស៊ុហ្គីគិ-ហ្ស៊ឹកិ(suguki-zuke) ដែលមានរសជាតិជូរ។ នៅខេត្តខាហ្គុសិម៉ា មានជ្រក់ល្ហុង ហៅថាប៉ាប៉ាអ៊ិយ៉ា-ហ្ស៊ឹកិ(papaya-zuke) ដែលធ្វើឡើងពីផ្លែល្ហុងជ្រក់ដោយមីសូ ឬ ទឹកស៊ីអ៊ីវ។ ការប្រែប្រួលជាច្រើនជាមួយនឹងប្រភេទជ្រក់ ជាង៦០០ប្រភេទដែលត្រូវបានគេនិយាយថាមាននៅទូទាំងប្រទេស។

*រូបភាពខាងលើ៖ ជ្រក់មានពណ៌យ៉ាងស្រស់ស្អាត*

*ថតដោយ តាគិសិម៉ា យ៉ូជិ* (Takishima Yoji) *រូបភាពដោយ* PIXTA

ទំព័រទី២៣៖

គុណតម្លៃរបស់ជ្រក់ គឺជាអាហារសុខភាពដែលកំពុងទទួលបានការកោតសរសើរឡើងវិញក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ បន្លែជ្រក់ជាមួយកន្ទក់ ហៅថា នឹកាហ្ស៊ីកិ (Nukazuke) កំពុងទាក់ទាញការចាប់អារម្មណ៍ព្រោះវាសម្បូរទៅដោយជាតិសរសៃ។ នឹកាហ្ស៊ីកិ ត្រូវបានធ្វើឡើងដោយកន្ទក់លាយជាមួយអំបិល និងទឹក រួចលាយវាឱ្យសព្វល្អ (ហៅថានឹកាដុកុ(nukadoko)) បន្ទាប់មកបន្ថែមបន្លែដូចជាត្រសក់ ត្រប់ និង ឆៃថាវ ផ្អាប់ទៅក្នុងនឹកាដុកុនោះ ដើម្បីបង្កើតរសជាតិពិសេស។ នឹកាហ្ស៊ីកិ ត្រូវបានគេនិយាយថាមានផ្ទុកទៅដោយបាតេរីឡាក់តូបាក់ស៊ីលូស (Lactobacillus) ដែលមានប្រសិទ្ធភាពក្នុងការសម្រួលពោះវៀន និងជំនួយឲ្យស្បែកស្អាត និងពង្រឹងភាពស៊ាំ។ វាក៏សម្បូរទៅដោយវីតាមីន B1 ផងដែរ ដែលត្រូវបានគេជឿថាអាចជំរុញការដាស់ឡើងវិញពីភាពអស់កម្លាំង។

ការប្រៀបធៀបរសជាតិពីតំបន់ផ្សេងៗគ្នា គឺជាវិធីមួយដើម្បីរីករាយជាមួយ ជ្រក់ប្រពៃណីទាំងនេះ។ នៅពេលទទួលទានជ្រក់ ឬ ត្ស៊ីកិម៉ុណុទាំងនេះ យើងនឹងទទួលបាននូវថាមពលដ៏សម្បូរបែប ស្របពេលនោះក៏ទទួលបានភាពរីករាយជាមួយក្លិនឈ្ងុយ និងភាពស្រស់គួរជាទីទាក់ទាញផងដែរ។

*រូបខាងលើ៖ ជ្រក់បន្លែស្រស់ យើងអាចរីករាយជាមួយរសជាតិបន្លែតាមរដូវ។*

*រូបក្រោមផ្នែកខាងឆ្វេង៖ យើងអាចបង្កើតរសជាតិតាមចំណូលចិត្តដោយបន្ថែម កុមប៊ឺ (សារ៉ាយសមុទ្រ) ឬ ម្ទេស ឬ ផ្សេងទៀត ទៅក្នុងនឹកាដុកុ (កន្ទក់ដែលមានលាយអំបិល និងទឹកច្របល់ចូលគ្នាសព្វ)។*

*រូបក្រោមផ្នែកកណ្តាល៖ នៅពេលដែលបន្លែទន់ យើងយកបន្លែចេញពីនឹកាដុកុ*

*រូបក្រោមផ្នែកខាងស្តាំ៖ លាងជម្រះកន្ទក់ រួចកាត់ជាដុំៗងាយស្រួលទទួលទាន់ ហើយដាក់លើចាន។*

ទំព័រទី២៤៖

## ដើរកំសាន្តប្រទេសជប៉ុន៖

**ខាម៉ាគីរ៉ា** ជាទីប្រជុំជនប្រវត្តិសាស្ត្រ រំលេចដោយសមុទ្រដ៏អស្ចារ្យ និងធម្មជាតិខៀវស្រងាត់

*រូបផ្នែកខាងលើ៖ នៅកំឡុងខែមិថុនា ផ្កាអាជិសៃជាច្រើនពាន់ដើម រួមទាំងហ៊ិម៉ិអាជិសៃដែលមានដើមកំណើតនៅប្រទេសជប៉ុន កំពុងរីកស្គុសស្គាយពណ៌ខៀវដ៏ស្រស់ស្អាត ពេញប្រាសាទមេហ្គិត្ស៊ឹអ៊ីន។*

ខាម៉ាគឺរ៉ា ហ៊ុមព័ទ្ធទៅដោយភ្នំលាតសន្ធឹងនៅទិសខាងកើត ខាងលិច និងខាងជើង ហើយទិសខាងត្បូងជាប់សមុទ្រ ផ្តល់នូវអារម្មណ៍ដ៏ស្រស់ស្រាយជាមួយនឹងធម្មជាតិ ពេញទីក្រុងតែម្តងដោយមានធាតុផ្សំទាំងពីរនេះគឺភ្នំ និងសមុទ្រ។

មិនត្រឹមតែប៉ុណ្ណោះ ក៏មានវត្ត និងព្រះវិហារជាទីសក្ការៈដ៏លេចធ្លោជាច្រើន ដូច្នេះសូមដើរកំសាន្តនៅទូទាំងខាម៉ាគឺរ៉ា ដែលជារាជធានីបុរាណនៃក្រុមគ្រួសារសាម៉ូរ៉ៃ (ស្ប៉ូហ៊្គីណាតិ)។

*(រូបផែនទីប្រទេសជប៉ុន៖ សមុទ្រជប៉ុន ទីក្រុងតូក្យូ ខាម៉ាគឺរ៉ានៅក្បែរទីក្រុងតូក្យូ ខេត្តអូសាកា មហាសមុទ្រប៉ាស៊ីហ្វិក)*

<u>ទំព័រទី២៥៖</u>

*រូបឆ្វេងផ្នែកខាងលើ៖ វត្តស៊ឹហ្គិម៉ុតុជិរ៉ា ត្រូវបានគេនិយាយថា គឺជាវត្តចំណាស់ជាងគេនៅខាម៉ាគឺរ៉ា។ កាំជណ្តើរស្លែ គឺអស្ចារ្យខ្លាំងណាស់។*

*រូបកណ្តាលផ្នែកខាងលើ៖ ផ្ទៃលាតសន្ធឹង បង្ហាញនូវទេសភាពនារដូវស្លឹកឈើជ្រុះនៅវត្តអេនហ្កាគឺជិ។*

*រូបស្តាំផ្នែកខាងលើ៖ ពេលវេលាដ៏ស្ងប់ស្ងាត់ នៃសួនច្បារបែបជប៉ុន នៅវត្តចូម្យ៉ូជិ។*

ខាម៉ាគឺរ៉ា គឺជាទីក្រុងដំបូងរបស់ជប៉ុន ជាទីដែលក្រុមគ្រួសារសាម៉ូរ៉ៃ (ស្ប៉ូហ៊្គីណាតិ) ត្រូវបានបង្កើតឡើងសម្រាប់ការអភិវឌ្ឍរបស់ខ្លួននៅចុងសតវត្សទី១២ និងទី១៣។ ទីនេះ មានប្រវត្តិសាស្ត្រដ៏សម្បូរបែប ពោរពេញដោយវិបុលភាព ជាមជ្ឈមណ្ឌលនៃប្រទេសជប៉ុន លើគ្រប់ទិដ្ឋភាពទាំងអស់ ចាប់ពីនយោបាយរហូតដល់វប្បធម៌។ ភាពទាក់ទាញនៃដំណើរកំសាន្តនូវទូទាំងខាម៉ាគឺរ៉ា គឺការដែលអាចបានទៅទស្សនាព្រះវិហារស៊ិនតូ និងវត្តតាមបែបព្រះពុទ្ធសាសនា ដែលជាសក្ខីភាពនៃប្រវត្តិសាស្ត្រដ៏យូរអង្វែង ទន្ទឹមនឹងការកោតសរសើរនូវទេសភាពផ្លាស់ប្តូរនៃរដូវទាំងបួន។ ដើម្បីរីករាយនឹងដំណើរកំសាន្តឱ្យពេញលេញ យើងខ្ញុំសូមចាប់ផ្តើមពីស្ថានីយគិតាខាម៉ាគឺរ៉ា។ វត្តល្បីៗជាច្រើននៅតំបន់នោះ រួមមានវត្តអេនហ្កាគឺជិ ដែលល្បីទៅដោយផ្កាសាគឺរ៉ារីកនៅនិទាឃរដូវ និងស្លឹកឈើប្រែពណ៌នៅសិសិររដូវ ព្រមទាំងប្រាសាទមេហ្គិត្ស៊ឹអ៊ិន ដែលជាទីគាប់ចិត្តត្រូវបានគេហៅថា វត្តផ្កាអាជិសៃ ជាមុខព្រួញនៃប្រភេទផ្កាជាច្រើនដែលអាចឱ្យយើងរីករាយទស្សនាបានពេញមួយឆ្នាំ។

បើអ្នកធ្វើដំណើរទៅទិសខាងត្បូងឆ្ពោះទៅកាន់ស្ថានីយខាម៉ាគឺរ៉ា ហើយក្រឡេកមើលរាជធានីបុរាណនេះ អ្នកនឹងបានឃើញព្រះវិហារត្ស៊ឹរឹហ្គាអុកា ហាឈិម៉ានហ្គឺ ដ៏ប្រណិតមានភាពអ៊ូអរជាមួយនឹងអ្នកចូលថ្វាយបង្គំ និងភ្ញៀវទេសចរ។ ព្រះវិហារនេះ មានវត្តមាននៅចំកណ្តាលខាម៉ាគឺរ៉ា និងអាចចាត់ទុកថាជាប្រភពនៃវប្បធម៌ផងដែរ។

ពិធីបុណ្យប្រពៃណីជាច្រើន ត្រូវបានប្រារព្ធនៅទីនេះ រួមមានពិធីបុណ្យចូលឆ្នាំថ្មីនៅថ្ងៃទី១ ខែមករា ពិធីបុណ្យយ៉ាប៊ឹសាមិ នៃអ្នកជិះសេះដ៏ក្លាហាន ស្លៀកសំលៀកបំពាក់បែបសាំម៉ុរ៉ៃនៅខាម៉ាគឺរ៉ាកំពុងប្រមាញ់ សាកសមនឹងការសម្តែងបាញ់ធ្នូ។

ចាប់ពីព្រះវិហារត្សឺរឹហ្គាអុកា ហាឈិម៉ានហ្គឺ សូមធ្វើដំណើរឆ្ពោះទៅទិសខាងកើតតាមបណ្តោយផ្លូវ កាណាហ្សាវ៉ាខៃដូ ដែលមានវត្ត និងប្រាសាទជាច្រើននៅជុំវិញ។ វត្តស៊ឹហ្គិម៉ុតុជិរ៉ា គឺជាវត្តបុរាណមួយ ហើយប្រវត្តិរបស់វា គឺអាចត្រូវបានរាប់ពីជណ្តើរស្លែ និងដំបូលស្បូវ។ យើងក៏អាចរីករាយនឹងទេសភាពលាតសន្ធឹងនៃទីក្រុងជាមូលដ្ឋានផងដែរ។ វត្តចូម្យ៉ូជិ គឺធំទូលាយ និងល្អឥតខ្ចោះសម្រាប់ការដើរលំហែ ទន្ទឹមនឹងបន្ទប់នៃពិធីលៀងតែនៅក្បែរបន្ទប់ធំផ្តល់នូវទិដ្ឋភាពដ៏ស្រស់ស្រាយនៃសួនច្បារជប៉ុន។

សម្រាប់អារម្មណ៍បែបនៅជនបទនៃរដូវទាំង៤នៅខាម៉ាគឺរ៉ា អ្នកគួរតែឈប់លំហែនៅផ្សារកសិករនៅក្បែរស្ថានីយខាម៉ាគឺរ៉ា។ អ្នកអាចទិញបន្លែតាមរដូវនៅខាម៉ាគឺរ៉ា ពីកសិករផ្ទាល់ច្រើនជាង២០នាក់ ដែលពួកគាត់លក់ផ្លាស់ប្តូរវេនគ្នា។ លំនៅដ្ឋាន និងភោជនីយដ្ឋានក្នុងតំបន់បានទទួលអត្ថប្រយោជន៍ពីទីផ្សារកសិករខាម៉ាគឺរ៉ា ចាប់តាំងពីពេលបើកដំបូងនៅឆ្នាំ១៩២៨។ បន្លែស្រស់ៗ និងចម្រុះពណ៌ចាប់ផ្តើមបើកលក់ពីម៉ោង៨ព្រឹករៀងរាល់ថ្ងៃ ហើយផ្សារកសិករគឺមានអតិថិជនទៅមកឥតដាច់ពេញមួយថ្ងៃរហូតដល់ម៉ោងបិទនៅពេលល្ងាច។

*រូបឆ្វេងផ្នែកបន្ទាប់ពីខាងលើ៖ ផ្សារកសិករខាម៉ាគឺរ៉ា។ បន្លែនៅខាម៉ាគឺរ៉ាត្រូវបានដាំដុះលើដីដែលមានជីវជាតិ ហ៊ុមព័ទ្ធដោយភ្នំ និងសមុទ្រ និងត្រូវបានគេនិយាយថា មានឱរសជាតិណាស់។*

*រូបស្តាំផ្នែកបន្ទាប់ពីខាងលើ៖ មានគ្រួសារកសិករជាច្រើននៅឯផ្សារ ជាមួយនឹងសាច់ញាតិតំណាបីជំនាន់*

*រូបឆ្វេងផ្នែកខាងក្រោម៖ ព្រះវិហារត្សឺរឹហ្គាអុកា ហាឈិម៉ានហ្គឺ គឺមានវត្តមាននៅកណ្តាលទីក្រុងខាម៉ាគឺរ៉ា*

*រូបស្តាំផ្នែកខាងក្រោម៖ ពិធីយ៉ាប៊ឹសាមិ មានប្រវត្តិប្រហែលជា៨០០ឆ្នាំមកហើយ។*

<u>ទំព័រទី២៦៖</u>
*រូបឆ្វេងផ្នែកខាងលើ៖ ទេសភាពនៅពីលើភ្នំខាងក្រោយវត្តកូម្យ៉ូជិ។ ភ្នំហ្វូជិជាទីគយគន់ ក៏អាចមើលឃើញផងដែរ។*
*រូបស្តាំផ្នែកខាងលើ៖ ឆ្នេរយឹអ៊ិហាម៉ា លាតសន្ធឹង ទៅដោយឆ្នេរខ្សាច់ដ៏ស្រស់ស្អាត។*

នៅក្នុងតំបន់ជុំវិញស្ថានីយ៍ ខាម៉ាគឺរ៉ា អ្នកមិនអាចខកខានជាមួយនឹងផ្លូវវ៉ាកាមិយ៉ាអុជិ ដែលជាផ្លូវទៅកាន់ព្រះវិហារត្សឺរឹហ្គាអុកា ហាឈិមានហ្គឺ និងផ្លូវកុម៉ាឈិដូរិ ដែលស្របគ្នានោះទេ។ បន្ថែមពីលើជម្រើសនៃការដើរទិញឥវ៉ាន់ដ៏សម្បូរបែប រួមទាំងវត្ថុអនុស្សាវរីយ៍បែបប្រពៃណី អ្នកអាចចូលទៅកាន់ភោជនីយដ្ឋានសាមញ្ញក្នុងចំណោមភោជនីយដ្ឋានជាច្រើន ឬ ទិញអាហារសម្រន់ដើម្បីញ៉ាំនៅពេលដើរកំសាន្ត។

ប្រសិនបើអ្នកធ្វើដំណើរទៅទិសខាងលិចពីស្ថានីយ៍ខាម៉ាគឺរ៉ា ឆ្ពោះទៅកាន់ ហាសិ អ្នកនឹងទៅដល់ប្រាសាទកូតុគឺអ៊ិន ដែលមានរូបសំណាកសំខាន់ គឺរូបសំណាកព្រះពុទ្ធអាមិដា(Amitabha)គង់សមាធិ ដែលជារូបសំណាកសម្បត្តិជាតិ ដែលត្រូវបានគេស្គាល់ថា ជាព្រះពុទ្ធដ៏អស្ចារ្យនៃខាម៉ាគឺរ៉ា។ ព្រះពុទ្ធរូបនេះ គឺជាចំណុចសំខាន់ដែលត្រូវតែទស្សនានៅខាម៉ាគឺរ៉ា ហើយវាត្រូវបានគេនិយាយថា ការសាងសង់បានចាប់ផ្តើមប្រហែលឆ្នាំ១២៥២ ហើយមានកម្ពស់១១.៣ម៉ែត្រ និងទម្ងន់១២១តោន ដែលអ្នកពិតជានឹងភ្ញាក់ផ្អើលជាមួយនឹងមាត្រដ្ឋានដ៏ធំរបស់រូបសំណាកនេះ។

តោះដើរបន្តិចទៀតទៅភាគខាងត្បូង ដើម្បីទៅសមុទ្រ។ នៅកណ្តាលឆ្នេរសមុទ្រ មានព្រំប្រទល់ជាប់នឹងទន្លេណាម៉ិរិ ដែលមានមាត់ឆ្នេរសមុទ្រផ្នែកខាងកើតត្រូវបានគេហៅថាឆ្នេរហៃរ្យុំគឺហ្សា ហើយផ្នែកខាងលិចត្រូវបានគេហៅថា ឆ្នេរយឺអ៊ិហ្គាហាម៉ា។

ឆ្នេរហៃរ្យុំគឺហ្សា មានទឹកថ្លាឆ្វង់ និងច្រាំងទឹកពាក់ដ៏ស្រស់ស្អាត។ ឈរយ៉ាងអស្ចារ្យក្នុងតំបន់នេះ គឺវត្តកូម្យ៉ូជិ។ នៅពីក្រោយវត្ត គឺជាភ្នំតេនស្ស៊ូ ដែលជាកន្លែងពេញនិយមជាមួយទេសភាពគួរឱ្យជក់ចិត្ត។ ដោយនៅជិតទីក្រុងតូក្យូ ឆ្នេរយឺអ៊ិហាម៉ា មានភាពរស់រវើកជាមួយនឹងមនុស្សជាច្រើននារដូវក្តៅ។ ឆ្នេរសមុទ្រលាតសន្ធឹងទៅភាគខាងលិចជាមួយនឹងកន្លែងទស្សនាដូចជា អ៊ិណាមឹរ៉ាហ្គាសាគិ និង ស៊ិឈិរិហ្គាហាម៉ា ដែលមានហាងកាហ្វេទាន់សម័យ និងផ្សេងៗជាច្រើនទៀត។ រថភ្លើងអិណុដេន ដែលកំពុងរត់កាត់ទីក្រុងតាមបណ្តោយឆ្នេរសមុទ្រជាមួយនឹងសមុទ្រ និងផ្ទៃមេឃពណ៌ខៀវនៅផ្ទៃខាងក្រោយ គឺជាទិដ្ឋភាពដែលធ្វើឱ្យអ្នកមានអារម្មណ៍ថាដូចជាកំពុងមើលសៀវភៅរូបភាព។

ម្ហូបដ៏ពេញនិយមដែលល្បីល្បាញនៅខាម៉ាគឺរ៉ា គឺស៊ិរ៉ាស៊ឺដុន(បាយចានគោមជាមួយត្រីល្អិតៗពណ៌សផ្លេកៗ)។ អ្នកអាចទទួលទានរសជាតិ ស៊ិរ៉ាស៊ិដុន ថ្មីៗស្រស់ៗបានចាប់ពីពាក់កណ្តាលខែមីនា រហូតដល់ដំណាច់ឆ្នាំ នៅពេលដែលការនេសាទត្រីស៊ិរ៉ាស៊ិ ត្រូវបានអនុញ្ញាត។ នៅក្នុងឆ្នាំងកាម៉ាក្តៅ ហើយដាក់ត្រីស៊ិរ៉ាស៊ឺឆៅ ដាំឱ្យពុះជាមួយអំបិល ត្រូវបានគេហៅថា កាម៉ាអាហ្គិស៊ិរ៉ាស៊ឺ។ ស៊ិរ៉ាស៊ឺដុន គឺជាការរួមបញ្ចូលគ្នានូវភាពទន់រលោង នៃកាម៉ាអាហ្គិស៊ិរ៉ាស៊ឺដែលត្រសុស ជាមួយនឹងត្រីស៊ិរ៉ាស៊ឺឆៅដ៏មានឱជារស នាំឲ្យវាមានរសជាតិឆ្ងាញ់គួរជាទីពេញចិត្តក្រៃលែង។

ខាម៉ាគឺរ៉ា ជាកន្លែងដែលអ្នកអាចរីករាយនឹងពណ៌ផ្សេងៗនៅពេលដែលរដូវកាលផ្លាស់ប្តូរ។ វាពោរពេញទៅដោយភាពទាក់ទាញ ដែលធ្វើឲ្យអ្នកចង់ទៅទស្សនាម្តងហើយម្តងទៀត។

*រូបថតផ្តល់សិទ្ធិដោយៈ ព្រះវិហារត្សឹរីហ្គាអុកា ហាឈិម៉ានហ្គ៊ឺ*, Italian Tomato Co., Ltd.

*រូបថតដោយ៖ PIXTA*

*រូបឆ្វេងផ្នែកខាងក្រោម៖ ផ្លូវកុម៉ាឈិ តែងតែមានភាពរស់រវើកជាមួយភ្ញៀវទេសចរជាច្រើន។*

*រូបកណ្តាលផ្នែកខាងក្រោម៖ ចម្រុះពណ៌នៃនំដានកុ(នំធ្វើពីម្សៅអង្ករ) ពីហាង"សាគូរ៉ា ណុ យ៉ឺមិុមិយ៉ា"។*

*រូបស្តាំផ្នែកខាងក្រោម៖ រថភ្លើងអិណុដេន គឺជាខ្សែរថភ្លើងក្នុងស្រុក ដែលល្បីល្បាញទូទាំងប្រទេស។*

<u>ទំព័រទី២៧៖</u>

*រូបខាងលើ៖ ព្រះពុទ្ធដ៏អស្ចារ្យនៃខាម៉ាគឺរ៉ា ជាមួយនឹងការបង្ហាញគួរឱ្យចាប់អារម្មណ៍នៃព្រះភ័ក្ត្រឱនចុះ។*

*រូបឆ្វេងផ្នែកកណ្តាល៖ ស៊ិរ៉ាស៊ឺដុន នៅហាងអាគិម៉ុតុ។ មានពីរស្រទាប់ គឺខាងលើ ជាត្រីស៊ិរ៉ាឆៅ និងខាងក្រោមជា កាម៉ាអាហ្គិស៊ិរ៉ាស៊ឺ។ ការរួមផ្សំដ៏ប្រណិតនេះត្រូវបានទទួលទានជាមួយបាយ។*

*រូបកណ្តាលផ្នែកកណ្តាល៖ ផ្តល់ជូនតែត្រីស៊ិរ៉ាស៊ឺស្រស់ៗដែលចាប់បាននៅពេលព្រឹកថ្ងៃនោះ។*

*រូបស្តាំផ្នែកកណ្តាល៖ "ហាងសាច់គោអាំងខាម៉ាគឺរ៉ាយ៉ាម៉ា" ដែលជាខួបលើកទី៥០ នៃការបង្កើតរបស់ខ្លួន។ សាច់គោអាំងដែលដុតដោយប្រុងប្រយ័ត្នក៏ជារសជាតិដ៏ល្អបំផុតដែលតំណាងឱ្យខាម៉ាគឺរ៉ាផងដែរ។*

**ផែនទីតំបន់ខាម៉ាគឺរ៉ា**

១. វត្តហ្ស៊ឺអុិរ៉ុគឺសាន អេនហ្គាគឺជិ
២. ប្រាសាទហ្វូហ្គេនហ្សាន មេហ្គិតស៊ឺអុិន
៣. វិហារតស៊ឺរឹហ្គាអុកា ហាឈិមានហ្គុ
៤. វត្តដៃហ្សុហ្សាន ស៊ឺហ្គិម៉ុតុ ជិរ៉ា
៥. វត្តតុកាសាន ចូម្យ៉ូជិ
៦. ផ្សារកសិករខាម៉ាគឺរ៉ា
៧. ព្រះពុទ្ធបដិមាធំ (ដៃប៊ឹស៊ឺ ខាម៉ាគឺរ៉ា) ក្នុងប្រាសាទកូតុគឺអុិន
៨. ប្រាសាទតេនស្យ៉ូហ្សាន រេនហ្គិអុិន ក្នុងវត្តកូម្យ៉ូជិ

ការធ្វើដំណើរ៖

- ទីក្រុងតូក្យូ (ប្រហែល៦០នាទី ដោយរថភ្លើងជេ អ យ៉ុកុស៊ឺកា (JR Yokosuka Line)) ⇒ ខាម៉ាគឺរ៉ា
- ព្រលានយន្តហោះហាណិដា (ប្រហែល ៣០នាទីដោយជើងយន្តហោះកេគ្យូ (Keikyu Airport Line)) ⇒ យ៉ុកុហាម៉ា (ប្រហែល២៥នាទី ដោយខ្សែរថភ្លើង ជេ អ យ៉ុកុស៊ឺកា (JR Yokosuka Line)) ⇒ ខាម៉ាគឺរ៉ា

ទំនាក់ទំនងព័ត៌មាន៖

នាយកដ្ឋានពាណិជ្ជកម្មទេសចរណ៍ ទីក្រុងខាម៉ាគឺរ៉ា

https://www.city.kamakura.kanagawa.jp/visitkamakura/en/

ទំព័រទី២៨៖

## វត្ថុអនុស្សាវរីយ៍របស់ជប៉ុន ㉑

**ឆត្របត់៖** ដំណើរការវិវត្តនៃការរចនា

ឆត្របត់មានឆ្អឹងដែលអាចបត់បាន ដែលធ្វើឱ្យវាតូចជាងឆត្រធម្មតា ហើយអាចដាក់ក្នុងកាបូបរបស់អ្នកយ៉ាងងាយស្រួល។ នៅប្រទេសជប៉ុន មនុស្សជាច្រើនតែងតែប្រើឆត្រនៅថ្ងៃដែលមានភ្លៀង ហើយប្រភេទឆត្រទាំងនេះមានប្រជាប្រិយភាព ព្រោះវាផ្តល់ភាពទុកចិត្តបាន ប្រសិនបើមានភ្លៀងភ្លាមៗ។

ឆត្រមានច្រើនប្រភេទ ចាប់ពីឆត្រស្រាលខ្លាំងមានទម្ងន់តិចជាង១០០ក្រាម រហូតដល់ ឆត្រស្តើងដែលមានកម្រាស់តិចជាង៣សង់ទីម៉ែត្រនៅពេលបត់ ហើយមានពណ៌ចម្រុះដែលគួរឱ្យរីករាយក្នុងការជ្រើសរើស។

ឆត្រជាទូទៅមានឆ្អឹងពី៦ទៅ៨ដើម ប៉ុន្តែប្រភេទរឹងមាំមួយចំនួនក៏មានឆ្អឹងច្រើនដើម្បីកែលម្អភាពធន់របស់វាប្រឆាំងនឹងខ្យល់។ ឆត្រដែលមានឆ្អឹងច្រើន គឺស្រដៀងនឹងឆត្របុរាណរបស់ជប៉ុន ដូច្នេះឆត្រខ្លះមានការរចនាលក្ខណៈរូបរាងពិសេស។

ស្ត្រីជប៉ុនជាច្រើនតែងបាំងឆត្រសម្រាប់ការពារកម្តៅថ្ងៃនារដូវក្តៅ។ គោលបំណងសំខាន់នៃឆត្រការពារកម្តៅថ្ងៃ គឺដើម្បីការពារស្បែកពីពន្លឺព្រះអាទិត្យ ប៉ុន្តែគុណតម្លៃនៃឆត្រការពារកម្តៅថ្ងៃនេះ កំពុងទទួលបានការកោតសរសើរជាថ្មី ក្នុងការការពារការសន្លប់ដោយត្រូវកម្តៅថ្ងៃខ្លាំងពេក ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ វត្ថុធាតុដើមត្រូវបានពង្រឹងដើម្បីទប់ស្កាត់មិនត្រឹមតែកាំរស្មីអ៊ុលត្រាវីយូឡេប៉ុណ្ណោះទេ ថែមទាំងការពារលកកម្តៅនិងពន្លឺផងដែរ។ ឆត្រការពារកម្តៅថ្ងៃភាគច្រើនក៏មានបន្ថែមការការពារជម្រាបទឹក ដូច្នេះឆត្រទាំងនោះក៏អាចប្រើជាឆត្រការពារភ្លៀងផងដែរ។

មិនថាភ្លៀង ឬ មានពន្លឺថ្ងៃទេ នៅពេលចេញទៅក្រៅដោយប្រើឆត្របត់ នាំមានអារម្មណ៍ស្រស់ថ្លាជានិច្ច។

*សហការជាមួយ៖* SMV JAPAN Co., Ltd., Shu's selection Co, LTD.

*រូបលើផ្នែកកណ្តាល៖ ឆត្រប្រភេទដែលមានចំនួនឆ្អឹង១២ និងច្រើនជាងនេះ។*
*រូបឆ្វេងផ្នែកខាងលើ៖ ឆត្រសាច់ក្រណាត់ប៉ូលីយេស្ទើ(polyester)នេះ មានស្រទាប់ការពារទឹកជ្រាប និងការពារកាំរស្មីយូវីបាន ៩៩.៩៩%។ ដូច្នេះវាអាចប្រើបានទាំងពេលមានពន្លឺថ្ងៃ និងភ្លៀង។*
*រូបឆ្វេងផ្នែកកណ្តាល៖ ប្រភេទស្តើងដែលមានកម្រាស់២.៥ សង់ទីម៉ែត្រនៅពេលបត់*
*រូបឆ្វេងផ្នែកខាងក្រោម៖ ឈុតឆត្រចម្រុះពណ៌ដែលមានមុខសត្វគួរឱ្យស្រលាញ់នៅដងឆត្រ។*

*ទស្សនាវដ្តី "និប៉ុនិកា" លេខ៣០*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/
*គេហទំព័រដែលផ្តល់ព័ត៌មានអំពីជប៉ុន* https://web-japan.org/